# ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

**អគ្គនាយកដ្ឋានកៅស៊ូ**

General Directorate of Rubber

# របាយការណ៍
# ស្តីពី
# លទ្ធផលការងារឆ្នាំ២០១៦ និងលើកទិសដៅ ការងារឆ្នាំ២០១៧ របស់អគ្គនាយកដ្ឋានកៅស៊ូ



# មាតិកា

| ល.រ | ចំណងជើង | ទំព័រ |
|---|---|---|


**១. សេចក្តីផ្តើម** ........ **១**

១.១ ប្រវត្តិកៅស៊ូធម្មជាតិ ........ ១

១.២ ផលប្រយោជន៍កៅស៊ូធម្មជាតិ ........ ២

១.៣ ស្ថានភាពកៅស៊ូធម្មជាតិលើពិភពលោកក្នុងឆ្នាំ២០១៦ ........ ២

១.៤ សេណារីយោកៅស៊ូធម្មជាតិឆ្នាំ២០១៦ (ANRPC, 2016) ........ ៣

**២. លទ្ធផលការងារសំខាន់ៗ ក្នុងឆ្នាំ២០១៦** ........ **៥**

២.១ ការងាររដ្ឋបាលនិងនីតិកម្ម ........ ៥

២.១.១ ការងាររដ្ឋបាល ........ ៥

២.១.២ ការងារនីតិកម្ម ........ ៦

២.២ ការងារផែនការនិងហិរញ្ញវត្ថុ ........ ៦

២.២.១ ការងារផែនការ ........ ៦

២.២.២ ការងារហិរញ្ញវត្ថុ ........ ៨

២.៣ ការងារអភិវឌ្ឍន៍ ........ ១១

២.៣.១ ស្ថិតិផ្ទៃដី ផលិតផល និងការនាំចេញកៅស៊ូធម្មជាតិ ........ ១១

២.៣.២ ស្ថិតិរោងចក្រ និងសិប្បកម្មកែច្នៃផលិតផលកៅស៊ូធម្មជាតិ ........ ១៣

២.៣.៣ ការងារផ្សព្វផ្សាយនិងបណ្តុះបណ្តាល ........ ១៤

២.៤ ការងារពិសោធន៍និងស្រាវជ្រាវ ........ ១៥

២.៥ ការងារសហប្រតិបត្តិការអន្តរជាតិ ........ ១៨

២.៥.១ សមាគមបណ្តាប្រទេសផលិតកៅស៊ូធម្មជាតិ (ANRPC) ........ ១៨

២.៥.២ ក្រុមប្រឹក្សាស្រាវជ្រាវនិងអភិវឌ្ឍន៍កៅស៊ូអន្តរជាតិ (IRRDB) ........ ២០

២.៥.៣ កិច្ចសហប្រតិបត្តិការជាមួយCIRAD ........ ២០

២.៥.៤ កិច្ចសហប្រតិបត្តិការជាមួយ CATAS ........ ២១

២.៥.៥ ទីភ្នាក់ងារបារាំងសម្រាប់ការអភិវឌ្ឍ (AFD) ........ ២១

២.៥.៦ កិច្ចសហប្រតិបត្តិការជាមួយសាកលវិទ្យាល័យអន្តរជាតិ ........ ២១

២.៥.៧ កិច្ចសហប្រតិបត្តិការជាមួយសាធារណរដ្ឋប្រជាមានិតចិន ........ ២២

២.៥.៨ ការរៀបចំគម្រោងអភិវឌ្ឍន៍កៅស៊ូក្នុងតំបន់ត្រីកោណអភិវឌ្ឍន៍កម្ពុជា ឡាវ និង វៀតណាម (CLV-DTA) ........ ២២

**៣. បញ្ហាប្រឈម** ........ **២២**

**៤. សំណូមពរ** ........ **២៣**

**៥. សន្និដ្ឋាន** ........ **២៣**

**៦. ទិសដៅការងារឆ្នាំ២០១៧** ........ **២៤**

## តារាង

១. តារាងទី១ មន្ត្រីរាជការតាមកម្រិតជំនាញ........................................ ០៦
២. តារាងទី២ ការប្រៀបធៀបវាងថវិកាអនុម័តឆ្នាំ២០១៥/២០១៦ ........................................ ០៨
៣. តារាងទី៣ ស្ថិតិផ្ទៃដីដំណាំកៅស៊ូឆ្នាំ២០១៦ (ហិកតា) ........................................ ១១
៤. តារាងទី៤ កម្មវិធីសន្និសីទ កិច្ចប្រជុំ និង សន្និបាតប្រចាំឆ្នាំ២០១៦ របស់ ANRPC........................................ ១៩
៥. តារាងទី៥ ព្រឹត្តិការណ៍សំខាន់របស់ ANRPC ក្នុងឆ្នាំ២០១៧........................................ ២០

## ក្រាហ្វិក

១. ក្រាហ្វិកទី១ ការប្រៀបធៀបថវិកាអនុវត្តនិងថវិកាអនុម័តឆ្នាំពី២០១០-២០១៦ ........................................ ០៩
២. ក្រាហ្វិកទី២ ការប្រមូលចំណូលរបស់អគ្គនាយកដ្ឋានកៅស៊ូឆ្នាំ២០១៦........................................ ១០
៣. ក្រាហ្វិកទី៣ អត្រាភាគរយនៃប្រភេទផ្ទៃដីចម្ការកៅស៊ូ២០១៦........................................ ១១
៤. ក្រាហ្វិកទី៤ ទំហំប្រភេទផ្ទៃដីដំណាំកៅស៊ូឆ្នាំ២០១២-២០១៦ (ហិកតា) ........................................ ១២
៥. ក្រាហ្វិកទី៥ ផ្ទៃដីកៅស៊ូចៀរជ័រ ថែទាំ និងសរុប ឆ្នាំ២០១២-២០១៦........................................ ១២
៦. ក្រាហ្វិកទី៦ ផលិតកម្មនិងការនាំចេញកៅស៊ូធម្មជាតិឆ្នាំ២០១២-២០១៦ ........................................ ១៣

## ឧបសម្ព័ន្ធ

១. ឧបសម្ព័ន្ធ ១ រចនាសម្ព័ន្ធអគ្គនាយកដ្ឋានកៅស៊ូ........................................ ២៦
២. ឧបសម្ព័ន្ធ ២ លទ្ធផលនៃការអនុវត្តចង្កោមសកម្មភាពថវិកាកម្មវិធី........................................ ២៧
៣. ឧបសម្ព័ន្ធ ៣ គោលដៅនៃការអនុវត្តចង្កោមសកម្មភាពថវិកាកម្មវិធីឆ្នាំ២០១៧ ........................................ ៣០
៤. ឧបសម្ព័ន្ធ ៤ ស្ថិតិ ផ្ទៃដី ផលិតផល និងការនាំចេញកៅស៊ូធម្មជាតិ ឆ្នាំ១៩៨០-២០១៦ ........................................ ៣៣
៥. ឧបសម្ព័ន្ធ ៥ ស្ថានភាពការងារអាជីវកម្ម ផលិតកម្ម និងនីហរ័ណកម្មកៅស៊ូ ឆ្នាំ២០១៦ ........................................ ៣៤
៦. ឧបសម្ព័ន្ធ ៦ ស្ថិតិដំណាំកៅស៊ូកម្ពុជាឆ្នាំ២០១៦ ........................................ ៣៥
៧. ឧបសម្ព័ន្ធ ៧ ស្ថិតិផ្ទៃដីអតីតចម្ការកៅស៊ូរដ្ឋ និងវិទ្យាស្ថានស្រាវជ្រាវកៅស៊ូកម្ពុជា(វសកក) ឆ្នាំ២០១៦... ៤១
៨. ឧបសម្ព័ន្ធ ៨ ស្ថិតិចម្ការកៅស៊ូលើសម្បទានដីសេដ្ឋកិច្ចឆ្នាំ២០១៦ ........................................ ៤២
៩. ឧបសម្ព័ន្ធ ៩ ស្ថិតិផ្ទៃដីកៅស៊ូគ្រួសារ ឆ្នាំ២០១៦........................................ ៤៧
១០. ឧបសម្ព័ន្ធ ១០ ស្ថិតិផ្ទៃដីកៅស៊ូលម្អិតតាមខេត្តឆ្នាំ២០១៦........................................ ៤៨
១១. ឧបសម្ព័ន្ធ ១១ តារាងក្រុមហ៊ុនសម្បទានដីសេដ្ឋកិច្ចដែលម្ចាស់វិនិយោគក្នុងស្រុក និង បរទេស លើដំណាំកៅស៊ូ ឆ្នាំ២០១៦ ........................................ ៥៤
១២. ឧបសម្ព័ន្ធ ១២ ស្ថិតិរោងចក្រ-សិប្បកម្មតាមខេត្ត ក្រុង-ស្រុក ប្រចាំឆ្នាំ២០១៦........................................ ៥៥

## បទបង្ហាញ

១. បទបង្ហាញទី១ លទ្ធផលការងារឆ្នាំ២០១៦ និងលើកទិសដៅការងារឆ្នាំ២០១៧របស់នាយកដ្ឋានអភិវឌ្ឍន៍កៅស៊ូ........................................ ៥៦
២. បទបង្ហាញទី២ លទ្ធផលការងារឆ្នាំ២០១៦ និងលើកទិសដៅការងារឆ្នាំ២០១៧របស់នាយកដ្ឋានទីផ្សារនិងសហប្រតិបត្តិការអន្តរជាតិ ........................................ ៦០

៣. បទបង្ហាញទី៣ លទ្ធផលការងារឆ្នាំ២០១៦ និងលើកទិសដៅការងារឆ្នាំ២០១៧របស់នាយកដ្ឋានកែច្នៃផលិតផលកៅស៊ូ ........ ៦៤
៤. បទបង្ហាញទី៤ លទ្ធផលការងារឆ្នាំ២០១៦ និងលើកទិសដៅការងារឆ្នាំ២០១៧របស់នាយកដ្ឋានរដ្ឋបាលនិងនីតិកម្ម ........ ៦៨
៥. បទបង្ហាញទី៥ លទ្ធផលការងារឆ្នាំ២០១៦ និងលើកទិសដៅការងារឆ្នាំ២០១៧របស់នាយកដ្ឋានផែនការ ហិរញ្ញវត្ថុ និងស្ថិតិ ........ ៧១
៦. បទបង្ហាញទី៦ លទ្ធផលការងារឆ្នាំ២០១៦ និងលើកទិសដៅការងារឆ្នាំ២០១៧របស់វិទ្យាស្ថានស្រាវជ្រាវកៅស៊ូកម្ពុជា ........ ៧៦

## រូបថត

១. រូបថតស្តីពីសកម្មភាពថ្នាក់ដឹកនាំអគ្គនាយកដ្ឋានកៅស៊ូ និងថ្នាក់ដឹកនាំក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ........ ៨១
២. រូបថតស្តីពីសកម្មភាពនាយកដ្ឋានអភិវឌ្ឍន៍កៅស៊ូ........ ៨៣
៣. រូបថតស្តីពីសកម្មភាពនាយកដ្ឋានទីផ្សារ និងសហប្រតិបត្តិការអន្តរជាតិ ........ ៨៤
៤. រូបថតស្តីពីសកម្មភាពនាយកដ្ឋានកែច្នៃផលិតផលកៅស៊ូ ........ ៨៥
៥. រូបថតស្តីពីសកម្មភាពនាយកដ្ឋានរដ្ឋបាល និងនីតិកម្ម ........ ៨៦
៦. រូបថតស្តីពីសកម្មភាពនាយកដ្ឋានផែនការ ហិរញ្ញវត្ថុ និងស្ថិតិ........ ៨៧
៧. រូបថតស្តីពីសកម្មភាពវិទ្យាស្ថានស្រាវជ្រាវកៅស៊ូកម្ពុជា........ ៨៨

# របាយការណ៍
## ស្តីពី
## លទ្ធផលការងារឆ្នាំ២០១៦ និងលើកទិសដៅការងារ ឆ្នាំ២០១៧ របស់អគ្គនាយកដ្ឋានកៅស៊ូ

### ១. សេចក្តីផ្តើម
### ១.១ ប្រវត្តិកៅស៊ូធម្មជាតិ

១- ដំណាំកៅស៊ូត្រូវបានដាំជាលើកដំបូងក្នុងប្រវត្តិសាស្ត្រកម្ពុជានាឆ្នាំ១៩១០ ដោយលោក ប៊ូ យ៉ា ជនជាតិបារាំង នៅក្នុងស្រុកព្រៃនប់ ខេត្តកំពត (បច្ចុប្បន្ន ខេត្តព្រះសីហនុ) លើផ្ទៃដីជាង១៥០ហិកតា។ ដល់ឆ្នាំ១៩២១ ទើបដំណាំកៅស៊ូជាលក្ខណៈឧស្សាហកម្មទ្រង់ទ្រាយធំ ត្រូវបានបង្កើតឡើងដោយក្រុមហ៊ុនវិនិយោគរបស់បារាំងធំៗ ចំនួន៥ នៅលើដីក្រហមបាសាល់នាខេត្តកំពង់ចាម ខេត្តក្រចេះ និងខេត្តរតនគិរី លើផ្ទៃដីទំហំជាង៥០.០០០ ហិកតា។ រហូតមកដល់ឆ្នាំ១៩៦៩ ដំណាំកៅស៊ូនៅកម្ពុជាបានពង្រីកផ្ទៃដីជាង៦៤.០០០ហិកតា ក្នុងនោះផ្ទៃដីចៀរមានជាង៣៩.០០០ហិកតា ដោយទទួលបានផលិតផលកៅស៊ូបានជាង៥០.០០០តោន សម្រាប់ការប្រើប្រាស់នៅក្នុងស្រុកនិងការនាំចេញទៅបរទេស។ នៅជំនាន់នោះ កម្ពុជាត្រូវបានអន្តរជាតិទទួលស្គាល់ច្បាស់ថាជាប្រទេសដែលមានចម្ការកៅស៊ូល្អ ដែលមានទិន្នផលនិងផលិតផលកៅស៊ូប្រកបដោយគុណភាពខ្ពស់នៅក្នុងតំបន់អាស៊ី។

២- ចាប់តាំងពីឆ្នាំ១៩៧០មក ដោយសារសង្គ្រាមក្នុងស្រុក ជាពិសេសដំណាក់កាលចុងក្រោយស្ថិតក្រោមរបបគ្រប់គ្រងរបស់ពួកខ្មែរក្រហម រាល់ហេដ្ឋារចនាសម្ព័ន្ធគ្រប់វិស័យស្ទើរដល់ឫសគល់ រហូតដល់អាយុជីវិតប្រជាជនរាប់លាននាក់ត្រូវបានទទួលរងគ្រោះមហន្តរាយយ៉ាងធ្ងន់ធ្ងរ និងស្ថានភាពចម្ការកៅស៊ូក៏ដូចជាជីវិតកម្មកររាប់ពាន់នាក់ ត្រូវទទួលរងគ្រោះថ្នាក់ និងចម្ការកៅស៊ូខូចខាតយ៉ាងធ្ងន់ធ្ងរ។

៣- ចាប់ពីឆ្នាំ១៩៨០ រដ្ឋាភិបាលបានរៀបចំដាក់ឱ្យដំណើរការស្តារ និងធ្វើអាជីវកម្មចម្ការកៅស៊ូចាស់ៗដែលនៅសេសសល់ឡើងវិញ រហូតមកដល់បច្ចុប្បន្ននិងបានដាក់ចេញនូវសេចក្តីប្រកាសស្តីពីការអភិវឌ្ឍដំណាំកៅស៊ូគ្រួសារនៅកម្ពុជា ព្រមទាំងបានផ្តល់សម្បទានដីសេដ្ឋកិច្ចសម្រាប់ដំណាំកៅស៊ូដល់វិនិយោគិនក្នុងស្រុកនិងបរទេស ក្នុងគោលបំណងប្រែក្លាយកម្ពុជា ទៅជាប្រទេសផលិតករកៅស៊ូដ៏មានសក្តានុពលនៅក្នុងតំបន់ និងជាប្រទេសផ្គត់ផ្គង់ផលិតផលកៅស៊ូមួយចំណែកចូលទៅក្នុងទីផ្សារពិភពលោក។ រហូតមកដល់បច្ចុប្បន្ននេះដំណាំកៅស៊ូនៅតែត្រូវបានគេប្រសិទ្ធនាមថាជា " **មាសស** " និងត្រូវបានរាជរដ្ឋាភិបាលកម្ពុជា យកចិត្តទុកដាក់ខ្ពស់បន្ទាប់ពីផលិតកម្មស្រូវ។ ជាពិសេសចាប់តាំងពីឆ្នាំ១៩៩៣ បន្ទាប់ពីរាជរដ្ឋាភិបាលបានធ្វើកំណែទម្រង់អតីតចម្ការកៅស៊ូរដ្ឋទាំង៧ ជាបន្តបន្ទាប់ពីស្វ័យភិបាលសេដ្ឋកិច្ច មកជាសហគ្រាសសាធារណៈមានលក្ខណៈសេដ្ឋកិច្ច និងចុងក្រោយបានធ្វើអវិនិយោគ ឱ្យទៅផ្នែកឯកជនគ្រប់គ្រងទាំងស្រុងក្នុងអំឡុងឆ្នាំ២០០៨-២០០៩។ ទន្ទឹមនឹងការធ្វើឯកជនភាវូបនីយកម្មអតីតចម្ការកៅស៊ូរដ្ឋ តម្លៃកៅស៊ូបានកើនឡើងខ្ពស់ជាបន្តបន្ទាប់ និងស្របពេលដែលរាជរដ្ឋាភិបាលបានផ្តល់សម្បទានដីសេដ្ឋកិច្ចដល់វិនិយោគិនក្នុងស្រុកនិងបរទេស ជាកត្តាជំរុញឱ្យឧស្សាហកម្មកៅស៊ូធម្មជាតិនៅកម្ពុជាទាំងចម្ការកសិឧស្សាហកម្ម និងចម្ការកៅស៊ូគ្រួសារ បានចាប់ផ្តើមបង្កើនសន្ទុះនិងមានការរីកចម្រើនមួយប្រកបដោយចីរភាព ទាំងនៅក្នុងផ្នែកដាំដុះ ការយកផល និងការនាំចេញផលិតផលកៅស៊ូផងដែរ។

## ១.២ ផលប្រយោជន៍កៅស៊ូធម្មជាតិ

៤- កៅស៊ូធម្មជាតិ គឺជាដំណាំយុទ្ធសាស្ត្រនិងសេដ្ឋកិច្ចមួយប្រភេទដែលផ្តល់ប្រយោជន៍ជាច្រើនដល់អ្នកដាំ ដល់សេដ្ឋកិច្ចជាតិ ដល់សង្គមទាំងមូល និងបរិស្ថាន ជាពិសេសបានចូលរួមលើកកម្ពស់ប្រាក់ចំណូលសេដ្ឋកិច្ចជាតិ និងសេដ្ឋកិច្ចគ្រួសារកសិករ ចូលរួមកាត់បន្ថយភាពក្រីក្រ តាមរយៈការបង្កើតការងារនិងមុខរបរមានស្ថិរភាពជូនប្រជាពលរដ្ឋនៅតាមតំបន់ជនបទ និងកាត់បន្ថយការធ្វើចំណាកស្រុក ផ្តល់ជាវត្ថុធាតុដើមសម្រាប់វិស័យឧស្សាហកម្ម ផលិតជាមុខទំនិញរាប់ពាន់មុខ សម្រាប់បម្រើតម្រូវការប្រើប្រាស់ប្រចាំថ្ងៃ ដូចជាសំបកកង់យានយន្ត សម្ភារក្នុងលំនៅដ្ឋាន ក្នុងផ្នែកវេជ្ជសាស្ត្រ (ស្រោមដៃពេទ្យ ស្រោមអនាម័យ។ល។) និងប្រើជាកំណល់សំណង់អាគារនិងស្ពានធំៗ ទប់ទល់ការដួលរលំដោយសាររញ្ជួយផែនដី។ល។ ផ្តល់ឈើសម្រាប់ប្រើប្រាស់សំណង់ ផលិតគ្រឿងសង្ហារឹម ជាឈើតន្នូរៈ ចូលរួមចំណែកជួយកាត់បន្ថយការកាប់បំផ្លាញព្រៃឈើធម្មជាតិ ការពារការហូរច្រោះដី និងជាគម្របបៃតងឡើងវិញ ដើម្បីចូលរួមក្នុងការថែរក្សាលំនឹងបរិស្ថាន ដោយកាត់បន្ថយឧស្ម័នផ្ទះកញ្ចក់ និងកាត់បន្ថយបម្រែបម្រួលអាកាសធាតុដែលជាបញ្ហាពិភពលោកសំខាន់មួយក្នុងពេលបច្ចុប្បន្ន។

## ១.៣ ស្ថានភាពកៅស៊ូធម្មជាតិលើពិភពលោកក្នុងឆ្នាំ២០១៦

៥- តម្លៃកៅស៊ូធម្មជាតិបានចាប់ផ្តើមស្ទុះងើបឡើងវិញកាលពីចុងឆ្នាំ២០១៦ ហើយសមាគមបណ្តាប្រទេសផលិតកៅស៊ូធម្មជាតិ (Association of Natural Rubber Producing Countries: ANRPC) រំពឹងថានិន្នាការនេះនឹងបន្តនៅក្នុងឆ្នាំ២០១៧ (TRA President View, 2016)។

៦- ជាមួយនឹងនិន្នាការថ្មីៗ នៃឧស្សាហកម្មកៅស៊ូធម្មជាតិលើទីផ្សារអន្តរជាតិ បានជះឥទ្ធិពលជាវិជ្ជមានដល់តម្លៃកៅស៊ូធម្មជាតិឱ្យមានការប្រែប្រួលដោយសារកត្តាមួយចំនួនរួមមាន៖ ការងើបឡើងវិញ នៃសេដ្ឋកិច្ចពិភពលោកដែលនាំមុខដោយសហរដ្ឋអាម៉េរិក តម្លៃប្រេងឆៅកើនឡើង អត្រាប្តូរប្រាក់ប្រទេសផលិតកៅស៊ូធៀបជាមួយប្រាក់ដុល្លារអាម៉េរិក យន្តការនានាក្នុងការរក្សាតុល្យភាពលើការផ្គត់ផ្គង់និងតម្រូវការ និងថ្មីៗនេះខេត្តចំនួន១២នៃភាគខាងត្បូងប្រទេសថៃ បានទទួលរងនូវគ្រោះទឹកជំនន់យ៉ាងធ្ងន់ធ្ងរ ដែលមិនធ្លាប់មានក្នុងរយៈពេល៣ទសវត្សរ៍កន្លងមកនេះ។ ប្រទេសថៃគឺជាប្រភព***អាងទឹកជ័រពិភពលោក (Latex Bowl of the World)*** ដែលផ្តល់ផលិតផលប្រមាណ៣៧% នៃការផ្គត់ផ្គង់កៅស៊ូធម្មជាតិពិភពលោក ហើយប្រមាណ៧០% នៃផលិតផលកៅស៊ូធម្មជាតិក្នុងប្រទេស ចេញមកពីបណ្តាខេត្តភាគខាងត្បូងនេះ (TRA President View, 2016)។

៧- យោងតាមការវាយតម្លៃបឋមដែលធ្វើឡើងដោយអាជ្ញាធរកៅស៊ូថៃ គ្រោះទឹកជំនន់នេះទំនងនឹងកាត់បន្ថយផលិតផលកៅស៊ូធម្មជាតិយ៉ាងហោចចំនួន៣៦០.០០០តោន ពីផលិតផលរបស់ប្រទេសថៃនៅក្នុងឆ្នាំ២០១៧។ ប្រទេសនេះនឹងអាចផលិតបានត្រឹមតែ៤.៣៨១លានតោន ក្នុងឆ្នាំ២០១៧ ដែលផ្ទុយនឹងការរំពឹងទុក ថានឹងអាចផលិតបានដល់ទៅ៤.៧៤១លានតោន។

៨- ជាការបន្ថែមចំពោះការថយចុះនៃកៅស៊ូធម្មជាតិនៅក្នុងប្រទេសថៃ ការផ្គត់ផ្គង់កៅស៊ូធម្មជាតិទូទាំងពិភពលោករួមទាំងបណ្តាប្រទេសដែលមិនមែនជាសមាជិក ANRPC បានធ្លាក់ចុះជាមធ្យម០,៦%ក្នុងឆ្នាំ នៅរវាងឆ្នាំ

២០១៤ និងឆ្នាំ២០១៦។ ទន្ទឹមនឹងនេះ តម្រូវការផលិតផលនេះបានកើនឡើងក្នុងអត្រា៣,២% ក្នុងរយៈពេលដូចគ្នា (TRA President View, 2016)។

៩- ដោយឡែកក្នុងឆ្នាំ២០១៦ យោងតាមទិន្នន័យថ្លៃកៅស៊ូធម្មជាតិនៅប្រទេសកម្ពុជា និន្នាការតម្លៃកៅស៊ូធម្មជាតិរបស់ ANRPC និន្នាការតម្លៃកៅស៊ូធម្មជាតិនៅ ប្រទេសម៉ាឡេស៊ី និងនិន្នាការតម្លៃកៅស៊ូធម្មជាតិប្រទេសថៃជាដើមឃើញថា តម្លៃកៅស៊ូធម្មជាតិទាំងនៅលើទីផ្សារក្នុងស្រុក និងក្រៅស្រុកមានការកើនឡើងគួរជាទីមោទកៈក្នុងត្រីមាសទី៤ ធៀបនឹងអំឡុងពេលដូចគ្នាក្នុងឆ្នាំ២០១៥។ សរុបមកលទ្ធផលនៃការងើបឡើងវិញនូវតម្លៃកៅស៊ូធម្មជាតិនេះ បានមកពី (១) ការងើបឡើងវិញនូវតម្លៃប្រេងនៅលើទីផ្សារពិភពលោក (២) បញ្ហាការផ្គត់ផ្គង់ធ្លាក់ចុះបណ្តាលមកពីគ្រោះទឹកជំនន់យ៉ាងធ្ងន់ធ្ងរនៅភាគខាងត្បូងប្រទេសថៃ (៣) ការរំពឹងទុកជាថ្មីនៃការងើបឡើងវិញយ៉ាងលឿននូវសេដ្ឋកិច្ចពិភពលោកនាំមុខដោយសហរដ្ឋអាម៉េរិក និង (៤) លទ្ធផលនៃភាពប្រសើរឡើងនូវតម្រូវការដែលបានរំពឹងទុក (TRA President View, 2016)។

## ១.៤ សេណារីយោកៅស៊ូធម្មជាតិឆ្នាំ២០១៦ (ANRPC, 2016)

១០- ផ្អែកតាមការព្យាកររបស់មូលនិធិរូបិយវត្ថុអន្តរជាតិ (International Monetary Fund: IMF) ដែលបានចេញផ្សាយក្នុងខែតុលាកន្លងមក សេដ្ឋកិច្ចពិភពលោកនឹងមានកំណើនក្នុងអត្រាប្រមាណ៣,៤% ក្នុងឆ្នាំ២០១៧ ធៀបនឹងឆ្នាំ២០១៦ ដែលមានអត្រាត្រឹម៣,១%ប៉ុណ្ណោះ ហើយសន្ទស្សន៍លើវាល់មុខទំនិញនឹងហក់ឡើងប្រមាណ១០% ក្នុងឆ្នាំ២០១៧ ធៀបនឹងឆ្នាំ២០១៦កន្លងមក។

១១- ការរំពឹងទុកថា កៅស៊ូធម្មជាតិក្នុងឆ្នាំ២០១៧ នឹងមានភាពប្រសើរឡើង គឺស្ថិតក្នុងអត្រាកំណើនគួរជាទីមោទកៈដែលជាកត្តាជម្រុញឱ្យការស្ទុះងើបឡើងវិញ នៃសេដ្ឋកិច្ចពិភពលោក ដោយសារតែយន្តការពង្រឹងទីផ្សាររួមនិងការអភិវឌ្ឍសេដ្ឋកិច្ច។ មូលនិធិរូបិយវត្ថុអន្តរជាតិ (IMF) បានព្យាករថា ភាពប្រសើរឡើងនៃតម្លៃទំនិញគួបផ្សំជាមួយនឹងតម្លៃប្រេងនៅលើទីផ្សារពិភពលោក គឺជាកត្តាវិជ្ជមានដែលជះឥទ្ធិពលទៅដល់តម្លៃកៅស៊ូធម្មជាតិ ហើយកំណើនសេដ្ឋកិច្ចពិភពលោក គឺស្ថិតក្នុងអត្រាប្រមាណ៣,៤% ដែលកំណើននេះអាស្រ័យលើភាពប្រសើរនៃយន្តការពង្រឹងទីផ្សាររួមនិងការអភិវឌ្ឍសេដ្ឋកិច្ច។

១២- ក្នុងឆ្នាំ២០១៧ កំណើនសេដ្ឋកិច្ចសហរដ្ឋអាម៉េរិកត្រូវបានរំពឹងថា នឹងកើនឡើងក្នុងអត្រា២,២% ដែលចេញមកពីតម្លៃថាមពលទាប និងភាពខ្សោយនៃប្រាក់ដុល្លារអាម៉េរិកពីអតីតកាល។ ចំណែកឯកំណើនសេដ្ឋកិច្ចជប៉ុនត្រូវបានព្យាករថា នឹងនៅតែមានភាពទន់ខ្សោយក្នុងអត្រាសក្តានុពល០,៥% ក្នុងឆ្នាំ២០១៦ និងមុននឹងកើនឡើងដល់អត្រា០,៦% ក្នុងឆ្នាំ២០១៧។ ផលិតផលក្នុងស្រុកសរុបរបស់ប្រទេសឥណ្ឌា នឹងបន្តកើនឡើងលឿនបំផុតក្នុងចំណោមប្រទេសដែលមានសេដ្ឋកិច្ចធំៗ ក្នុងអត្រាកំណើនព្យាករណ៍៧,៦% នាក្នុងឆ្នាំ២០១៦-២០១៧។

១៣- សេដ្ឋកិច្ចប្រទេសចិនមានកំណើនក្នុងអត្រា៦,៦% ក្នុងឆ្នាំ២០១៦ ព្រោះមានការគាំទ្រផ្នែកគោលនយោបាយពីរដ្ឋាភិបាល ហើយត្រូវបានគេរំពឹងថាអាចនឹងមានការធ្លាក់ចុះបន្តិចក្នុងអត្រា៦,២% នាឆ្នាំ២០១៧នេះ ដោយសារតែភាពអវត្តមាន នៃការគាំទ្រផ្នែកគោលនយោបាយ និងការជំរុញលើកទឹកចិត្តបន្តទៀតពីរដ្ឋាភិបាល។ ដោយឡែកកំណើនសេដ្ឋកិច្ចក្នុងតំបន់ប្រទេសចាយប្រាក់យូរ៉ូទាំងមូល ត្រូវបានព្យាករថានឹងធ្លាក់ចុះបន្តិចពីអត្រា១,៧% ក្នុងឆ្នាំ២០១៦ មកត្រឹម១,៥% ក្នុងឆ្នាំ២០១៧។ អត្រាកំណើនធ្លាក់ចុះទាបនេះ គឺបណ្តាលមកពី

ទំនុកចិត្តរបស់វិនិយោគិនចុះខ្សោយជាងមុន ព្រោះការព្យាករតម្លៃប្រេងឆៅគិតជាមធ្យមពី៤៣ដុល្លារអាម៉េរិកក្នុង១បារ៉ែល ក្នុងឆ្នាំ២០១៦ នឹងកើនឡើងដល់៥១ដុល្លារអាម៉េរិកក្នុង១បារ៉ែលនៅឆ្នាំ២០១៧នេះ គួបផ្សំជាមួយនឹងអង្គការនៃបណ្តាប្រទេសនាំប្រេងចេញ (Organization of Petroleum Exporting Countries-OPEC) បានយល់ព្រមកាត់បន្ថយចំនួន១,២លានបារ៉ែល នៃទិន្នផលប្រេងឆៅប្រចាំថ្ងៃពីផែនការផលិតកម្មរបស់ខ្លួនមកត្រឹមតែ៣២,៥លានបារ៉ែលក្នុងមួយថ្ងៃ ក្នុងរយៈពេល៦ខែគិតចាប់ពីខែមករា ឆ្នាំ២០១៧នេះតទៅ (TRA President View, 2016)។

១៤- ផ្អែកតាមទស្សនវិស័យថាមពលសហរដ្ឋអាម៉េរិករយៈពេលខ្លីនៅថ្ងៃទី១០ ខែមករានេះ ANRPC បានលើកឡើងថា ប្រេងឆៅត្រូវបានរំពឹងថានឹងមានតម្លៃជាមធ្យម៥៣ដុល្លារក្នុង១បារ៉ែល ក្នុងឆ្នាំ២០១៧ គឺកើនឡើងក្នុងអត្រា២០,៥% បើធៀបនឹងឆ្នាំ២០១៦ មានតម្លៃត្រឹមតែ៤៤ដុល្លារក្នុង១បារ៉ែល។ ANRPC បានបន្ថែមទៀតថាដោយឡែក កៅស៊ូសំយោគសម្រាប់ជាវត្ថុធាតុដើមនឹងមានតម្លៃខ្ពស់ក្នុងឆ្នាំ២០១៧ ដែលជាហេតុផ្តល់នូវលទ្ធផលល្អប្រសើរនាពេលអនាគតសម្រាប់អ្នកដាំកៅស៊ូធម្មជាតិ (TRA President View, 2016)។

១៥- ចំណែកឯលក្ខខណ្ឌ នៃការព្យាករកៅស៊ូធម្មជាតិ ជាពិសេសការវិភាគលើតម្លៃកៅស៊ូ ចាំបាច់ត្រូវពិចារណាទៅលើកត្តាមូលដ្ឋានមួយចំនួនរួមមានកត្តាផលិតកម្ម តម្រូវការប្រើប្រាស់ និងកត្តាអតិរេក។ អ្នកសេដ្ឋវិទូកៅស៊ូបានរំពឹងទុកថា នឹងមានកំណើនខ្លាំងជាងមុននៅក្នុងផលិតកម្មកៅស៊ូធម្មជាតិនាអំឡុងពេល២-៣ឆ្នាំខាងមុខ ក្នុងអត្រាកំណើនរង្វង់២,៧% គិតចាប់ពីឆ្នាំ២០១៦-២០១៨ ដើម្បីសម្រេចបាននូវផលិតផលសរុបប្រមាណ១៣,៣លានតោន នាឆ្នាំ២០១៨។ រីឯកំណើននៃការប្រើប្រាស់កៅស៊ូគិតជាមធ្យមសម្រាប់ឆ្នាំ២០១៦-២០១៨ គឺស្ថិតក្នុងអត្រាប្រមាណ៣% ដែលអត្រាកំណើននេះនឹងនាំឱ្យមានតម្រូវការប្រើប្រាស់កៅស៊ូធម្មជាតិនិងកៅស៊ូសំយោគប្រមាណ២៩,១៦លានតោន នាឆ្នាំ២០១៨ ទោះបីយ៉ាងណាគេរំពឹងថា អត្រាកំណើននៃការប្រើប្រាស់កៅស៊ូក្នុងឆ្នាំ២០១៧ និងឆ្នាំ២០១៨ មានភាពប្រសើរឡើង និងច្រើនជាងក្នុងឆ្នាំ២០១៦។

១៦- យោងតាមទិន្នន័យ នៃអង្គភាពបញ្ញាសេដ្ឋវិទូបានលើកឡើងថា ក្នុងឆ្នាំ២០១៧ ផលិតកម្មកៅស៊ូធម្មជាតិគួរបង្កើនផលិតភាពឱ្យបានក្នុងរង្វង់អត្រា២,៥%គួបផ្សំជាមួយនឹងតម្លៃកៅស៊ូខ្ពស់ និងលក្ខខណ្ឌអាកាសធាតុអំណោយផលបន្ថែមទៀតនោះ។ កំណើននៃផលិតផលកៅស៊ូធម្មជាតិត្រូវបានគេរំពឹងថា នឹងមានល្បឿនយឺតបន្តិចក្នុងឆ្នាំ២០១៨ គិតជាមធ្យមប្រចាំឆ្នាំក្នុងអត្រាប្រមាណ២,៣%។ កំណើននៃការប្រើប្រាស់សកលត្រូវបានព្យាករណ៍ថា កើនឡើងថេរក្នុងអត្រាមធ្យមប្រចាំឆ្នាំប្រមាណ២% នាឆ្នាំ២០១៧-២០១៨ ដោយសារតម្រូវការនៅទូទាំងតំបន់ទាំងអស់ គួបផ្សំជាមួយនឹងកំណើនសេដ្ឋកិច្ចខ្លាំងជាងមុនបន្តិចនៅក្នុងឆ្នាំ២០១៧ ជាពិសេសក្នុងបណ្តាប្រទេសកំពុងអភិវឌ្ឍន៍ដែលកំពុងតែធ្វើសមាហរណកម្មខ្លួន។

១៧- សមាគមកៅស៊ូប្រទេសថៃ ប្រកាន់យកឥរិយាបថវិជ្ជមាន លើទស្សនវិស័យទីផ្សារកៅស៊ូធម្មជាតិ ដោយសារតែកៅស៊ូធម្មជាតិ បានជួយរួមចំណែកដល់កំណើនសេដ្ឋកិច្ចពិភពលោក។ ក្រៅពីនេះ ក្រុមប្រឹក្សាកៅស៊ូត្រីភាគីអន្តរជាតិ (International Tripartite Rubber Council- ITRC) និងរដ្ឋាភិបាលថៃ បាននិងកំពុងផ្តល់នូវដំណោះស្រាយតាមគ្រោងការណ៍ និងយន្តការជាច្រើនដើម្បីរក្សាស្ថិរភាពតម្លៃកៅស៊ូធម្មជាតិ។ យន្តការទាំងនេះនឹងធានាបាននូវស្ថានភាពកៅស៊ូធម្មជាតិល្អប្រសើរគួបផ្សំនឹងគ្រោងការណ៍ ដែលបានសន្យារបស់ ITRC រួមមាន៖ (១) ការឯកភាពលើកូតានាំចេញក្នុង អំឡុងពេលចាប់ពីខែកញ្ញាដល់ខែធ្នូ ឆ្នាំ២០១៦ (២) កិច្ចសហប្រតិបត្តិការស្តីពី ការប្រើប្រាស់កៅស៊ូធម្មជាតិក្នុងការស្ថាបនាហេដ្ឋារចនាសម្ព័ន្ធរូបវន្តដូចជាស្ពាន ផ្លូវថ្នល់។ល។

និង (៣) ផ្តល់ពានរង្វាន់ដល់គំនិតច្នៃប្រឌិតផលិតផលកៅស៊ូធម្មជាតិថ្មី សំដៅលើកទឹកចិត្តដល់ការប្រើប្រាស់កៅស៊ូធម្មជាតិ (TRA President View, 2016)។

១៨- ជាការសន្និដ្ឋាន គេមានជំនឿដោយសុទិដ្ឋិនិយមថា ការទំនាក់ទំនងនិងសហការយូរអង្វែងជាមួយវិស័យដែលពាក់ព័ន្ធតួយ៉ាងដូចជា ភ្នាក់ងាររដ្ឋាភិបាល វិស័យឯកជន អ្នកដាំកៅស៊ូ ប្រតិបត្តិករកៅស៊ូនានា រួមទាំងផលិតករកៅស៊ូធម្មជាតិចម្បងទាំងបី គឺប្រទេសថៃ ឥណ្ឌូនេស៊ី និងម៉ាឡេស៊ី ក្នុងការផ្តល់ទិសដៅនិងដំណោះស្រាយជាយុទ្ធសាស្ត្រដើម្បីស្ថិរភាពតម្លៃនៅក្នុងរយៈពេលខ្លី និងវែង ទីបំផុតនឹងឈានទៅរក្សាបាននូវស្ថិរភាពតម្លៃកៅស៊ូធម្មជាតិនៅលើទីផ្សារពិភពលោក (TRA President View, 2016)។

## ២. លទ្ធផលការងារសំខាន់ៗ ក្នុងឆ្នាំ២០១៦

ក្នុងឆ្នាំ២០១៦កន្លងទៅ អគ្គនាយកដ្ឋានកៅស៊ូបានអនុវត្តការងារចម្បងៗ ក្នុងស្មារតីទទួលខុសត្រូវខ្ពស់និងយ៉ាងសកម្ម ដោយទទួលបានលទ្ធផលដូចខាងក្រោម៖

## ២.១ ការងាររដ្ឋបាលនិងនីតិកម្ម

### ២.១.១ ការងាររដ្ឋបាល

១៩- អនុក្រឹត្យលេខ១៨៨អនក្រ.បក ចុះថ្ងៃទី១៤ ខែវិច្ឆិកា ឆ្នាំ២០០៨ របស់រាជរដ្ឋាភិបាលកម្ពុជា អគ្គនាយកដ្ឋានកៅស៊ូមានបេសកកម្មធានាការអភិវឌ្ឍ និងការគ្រប់គ្រងវិស័យកៅស៊ូគ្រប់ផ្នែក ស្របតាមគោលនយោបាយរបស់រាជរដ្ឋាភិបាល សំដៅរួមចំណែកជំរុញសេដ្ឋកិច្ចជាតិ សេដ្ឋកិច្ចគ្រួសារ និងសង្គម កាត់បន្ថយភាពក្រីក្រ លើកកម្ពស់គុណភាពផលិតផលកៅស៊ូ ដើម្បីធានាដល់ការប្រកួតប្រជែងនៅលើទីផ្សារ តាមរយៈការផ្តល់សេវាស្រាវជ្រាវ និងការផ្ទេរបច្ចេកវិទ្យាប្រកបដោយប្រសិទ្ធភាព ព្រមទាំងការអភិវឌ្ឍ និងការគ្រប់គ្រងខ្សែចង្វាក់ផលិតកម្មអាជីវកម្ម កែច្នៃ សំដៅជំរុញពាណិជ្ជកម្មផលិតផលកៅស៊ូ។

២០- អគ្គនាយកដ្ឋានកៅស៊ូ មានភារកិច្ចធ្វើជាសេនាធិការឱ្យក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ លើការងារជាអាទិ៍៖ រៀបចំ និងអនុវត្តយុទ្ធសាស្ត្រ គោលនយោបាយ ចក្ខុវិស័យ គោលដៅបេសកកម្ម និងកម្មវិធីអភិវឌ្ឍន៍វិស័យកៅស៊ូនៅកម្ពុជា សម្រាប់រយៈពេលមធ្យម និងវែង កសាងមូលដ្ឋានគតិយុត្ត លិខិតបទដ្ឋាន ច្បាប់ស្តីពីការគ្រប់គ្រង និងអភិវឌ្ឍកៅស៊ូធានារាល់ដំណើរការផ្សេងៗទៀត ដែលមានការពាក់ពន្ធដល់វិស័យកៅស៊ូទូទាំងប្រទេស ព្រមទាំងភារកិច្ចផ្សេងៗទៀត ដែលថ្នាក់ដឹកនាំក្រសួងប្រគល់ឱ្យ។

២១- អគ្គនាយកដ្ឋានកៅស៊ូមាននាយកដ្ឋានជំនាញចំនួន០៥ និងវិទ្យាស្ថានស្រាវជ្រាវកៅស៊ូកម្ពុជាចំនួន០១ជាសេនាធិការក្នុងការបំពេញភារកិច្ចទទួលខុសត្រូវតាមជំនាញសំដៅជំរុញ ពង្រឹង តាមដាន ស្រាវជ្រាវ និងអភិវឌ្ឍវិស័យកៅស៊ូនៅទូទាំងប្រទេស (ឧបសម្ព័ន្ធទី១)។

២២- អគ្គនាយកដ្ឋានមានមន្ត្រីរាជការសរុបចំនួន១៩៤នាក់ ក្នុងនោះស្រីមានចំនួន៥៤នាក់ដែលកំពុងបម្រើការងារនៅតាមនាយកដ្ឋាន និងវិទ្យាស្ថានស្រាវជ្រាវកៅស៊ូកម្ពុជា។ ការបែងចែកមន្ត្រីរាជការតាមកម្រិតជំនាញដូចមានខាងក្រោម៖

តារាងទី១ មន្ត្រីរាជការតាមកម្រិតជំនាញ

| ល.រ | បរិយាយ | កម្រិតសញ្ញាបត្រ | | | | | |
|---|---|---|---|---|---|---|---|
| | | បណ្ឌិត | អនុបណ្ឌិត | បរិញ្ញាបត្រ | មធ្យម | គ្មាន | សរុប |
| ១ | ថ្នាក់ដឹកនាំអគ្គនាយកដ្ឋាន | ១ | ៣ | - | ១ | - | **៥** |
| ២ | នា.រដ្ឋបាល និងនីតិកម្ម | - | ៤ | ១៣ | ៨ | ១៧ | **៤២** |
| ៣ | នា.អភិវឌ្ឍន៍កៅស៊ូ | ១ | - | ២៣ | ១ | ៤ | **២៩** |
| ៤ | នា.ផែនការ ហិរញ្ញវត្ថុ និងស្ថិតិ | - | ៤ | ១១ | ៣ | ៦ | **២៤** |
| ៥ | នា.កែច្នៃផលិតផលកៅស៊ូ | - | ១ | ១១ | ២ | ៤ | **១៨** |
| ៦ | នា.ទីផ្សារ និងសហ.អន្តរជាតិ | - | ២ | ១០ | ៤ | ៧ | **២៣** |
| ៧ | វិទ្យាស្ថានស្រាវជ្រាវកៅស៊ូកម្ពុជា | ១ | ១០ | ២៩ | ៦ | ៧ | **៥៣** |
| | សរុប | **៣** | **២៤** | **៩៧** | **២៥** | **៤៥** | **១៩៤** |

### ២.១.២ ការងារនីតិកម្ម

២៣- ក្នុងឆ្នាំ២០១៦ អគ្គនាយកដ្ឋានកៅស៊ូបានរៀបចំសេចក្តីព្រាងច្បាប់ស្តីពីកៅស៊ូ លិខិតបទដ្ឋានគតិយុត្តនានាដូចជាសេចក្តីព្រាងប្រកាសស្តីពីនីតិវិធីនៃការគ្រប់គ្រងស្នាក់ការប្រមូលទិញជ័រកៅស៊ូគ្រួសារ។ ចំពោះសេចក្តីព្រាងប្រកាសស្តីពីនីតិវិធី នៃការគ្រប់គ្រងស្នាក់ការប្រមូលទិញជ័រកៅស៊ូគ្រួសារ បានឆ្លងកិច្ចប្រជុំអន្តរនាយកដ្ឋានរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និងបានធ្វើការកែសម្រួលតាមស្មារតីអង្គប្រជុំ ផ្ញើជូនឯកឧត្តម-រដ្ឋមន្ត្រី ដើម្បីពិនិត្យ និងចុះហត្ថលេខារួចហើយ។ បានចូលរួមដោះស្រាយទំនាស់ដីចម្ការកៅស៊ូដែលពាក់ព័ន្ធជាមួយបណ្តាក្រុមហ៊ុនចម្ការកៅស៊ូមួយចំនួន។

ការងាររបស់នាយកដ្ឋានរដ្ឋបាល និងនីតិកម្មមានលម្អិតក្នុងបទបង្ហាញទី៤។

## ២.២ ការងារផែនការនិងហិរញ្ញវត្ថុ

### ២.២.១ ការងារផែនការ

២៤- ដើម្បីសម្រេចគោលបំណង និងគោលដៅវិស័យកសិកម្មដែលបានកំណត់ក្នុងផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ ២០១៤-២០១៨ និងផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យកសិកម្ម២០១៤-២០១៨ ពិសេសផ្នែកកៅស៊ូ។ អគ្គនាយកដ្ឋានកៅស៊ូដែលជាសេនាធិការរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ បានអនុវត្តអនុកម្មវិធីចំនួន៦ ដែលក្នុងនោះមានចង្កោមសកម្មភាពចំនួន៣៣សម្រាប់ទ្រទ្រង់និងអនុវត្តៈ

១. អនុកម្មវិធីទី១.១១៖ ជំរុញការវិនិយោគនិងអភិវឌ្ឍន៍ដំណាំកៅស៊ូ ប្រកបដោយប្រសិទ្ធភាពសេដ្ឋកិច្ចខ្ពស់និងចីរភាព

- ១.១១.១ បណ្តុះបណ្តាលជំនាញចៀរជ័រដល់កសិករកៅស៊ូគ្រួសារ
- ១.១១.២ ផ្សព្វផ្សាយបច្ចេកទេសដំណាំកៅស៊ូដល់កសិករកៅស៊ូគ្រួសារ
- ១.១១.៣ ស្រង់ស្ថិតិនិងកំណត់ទីតាំងចម្ការកៅស៊ូគ្រួសារ
- ១.១១.៤ បណ្តុះបណ្តាលបច្ចេកទេសដំណាំកៅស៊ូដល់មន្ត្រីបង្គោល
- ១.១១.៥ ពង្រឹងនិងចងក្រងសហគមន៍កសិករកៅស៊ូគ្រួសារ។

២. អនុកម្មវិធីទី១.១២៖ ជំរុញខ្សែចង្វាក់តម្លៃកៅស៊ូឱ្យបានល្អ

- ១.១២.១ បណ្តុះបណ្តាល និងផ្សព្វផ្សាយពីទីផ្សារកៅស៊ូ ដល់សហគមន៍កៅស៊ូគ្រួសារឱ្យបង្កើតមជ្ឈមណ្ឌលលក់ដូរកៅស៊ូរួម
- ១.១២.២ ផ្តល់ព័ត៌មានពីការផ្គត់ផ្គង់តម្រូវការ និងតម្លៃកៅស៊ូដល់ប្រតិបត្តិករកៅស៊ូ។

៣. អនុកម្មវិធីទី១.១៣៖ លើកកម្ពស់គុណភាពផលិតផលកៅស៊ូ

- ១.១៣.១ ស្រង់ស្ថិតិរោងចក្រ-សិប្បកម្មកែច្នៃផលិតផលកៅស៊ូ
- ១.១៣.២ ផ្សព្វផ្សាយបច្ចេកទេសកែច្នៃដល់ប្រតិបត្តិករកៅស៊ូ
- ១.១៣.៣ ផ្សព្វផ្សាយ និងបណ្តុះបណ្តាលបច្ចេកទេសកែច្នៃកៅស៊ូសន្លឹក (USS) ដល់សហគមន៍កៅស៊ូគ្រួសារ។

៤. អនុកម្មវិធីទី១.១៤៖ លើកកម្ពស់ការគ្រប់គ្រង និងបណ្តុះបណ្តាលធនធានមនុស្សក្នុងផ្នែកកៅស៊ូ

- ១.១៤.២ រៀបចំសេចក្តីព្រាងលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធវិស័យកៅស៊ូ
- ១.១៤.៣ ផ្សព្វផ្សាយលិខិតបទដ្ឋានគតិយុត្តនានាពាក់ព័ន្ធវិស័យកៅស៊ូ
- ១.១៤.៤ បណ្តុះបណ្តាលសមត្ថភាពជំនាញដល់ប្រតិបត្តិករកៅស៊ូ។

៥. អនុកម្មវិធីទី១.១៥៖ ពង្រឹងការងាររដ្ឋបាល និងអភិបាលកិច្ចក្នុងផ្នែកកៅស៊ូ

- ១.១៥.១ ពង្រឹងប្រសិទ្ធភាពនៃការអនុវត្តថវិកា
- ១.១៥.២ បណ្តុះបណ្តាលការរៀបចំ និងគ្រប់គ្រងអនុកម្មវិធី
- ១.១៥.៣ រៀបចំសន្និបាតឬប្រជុំបូកសរុបប្រចាំឆ្នាំ
- ១.១៥.៤ តាមដានការអនុវត្តផែនការកម្មវិធីវិនិយោគកៅស៊ូនិងវាយតម្លៃលទ្ធផលដែលសម្រេចបាន
- ១.១៥.៥ គាំទ្រការសម្របសម្រួលការងារកិច្ចការរដ្ឋបាល។

៦. អនុកម្មវិធីទី១.១៦៖ លើកកម្ពស់គុណភាពពូជកៅស៊ូថ្មី និងប្រសិទ្ធភាព គុណភាពផលិតផលកៅស៊ូ

- ១.១៦.១ រៀបចំច្បារបង្កាត់ពូជថ្មី ថែទាំ និងបង្កាត់ពូជ
- ១.១៦.២ បង្កើតចំការពិសោធក្លូនទ្រង់ទ្រាយធំចំនួនពីរ
- ១.១៦.៣ តាមដាន និងស្រង់ទិន្នន័យចំការពិសោធន៍ប្រាំតំបន់
- ១.១៦.៤ គ្រប់គ្រងថែទាំច្បារពូជក្នុងស្ថានីយ៍អនុវត្ត
- ១.១៦.៥ គ្រប់គ្រង កៅស៊ូមិនទាន់ឱ្យផល និងថ្នាលបណ្តុះកូនកៅស៊ូ
- ១.១៦.៦ ស្រាវជ្រាវការប្រើជីលើកៅស៊ូមិនទាន់ឱ្យផល និងកៅស៊ូឱ្យផល
- ១.១៦.៧ បន្តការតាមដានចំការពិសោធន៍ផ្នែកដាំដុះ និងការពារ
- ១.១៦.៨ ផ្សព្វផ្សាយបច្ចេកទេសដាំដុះ ថែទាំ និងជំងឺកៅស៊ូដល់កសិករ
- ១.១៦.៩ ពិសោធន៍ស្រាវជ្រាវលើគុណភាពដី(ដោយដំណាំគម្របដី)
- ១.១៦.១០ ពិសោធន៍តាមដានប្រព័ន្ធចង្វាក់ចៀរជ័ររង្វើលនៅស្ថានីយ៍អនុវត្ត
- ១.១៦.១១ វិភាគសរីរៈទឹកជ័រកៅស៊ូចំការពិសោធន៍នានាក្នុងស្ថានីយ៍អនុវត្ត
- ១.១៦.១២ បើកវគ្គបណ្តុះបណ្តាលបច្ចេកទេសប្រមូលផលទឹកជ័រ
- ១.១៦.១៣ ធ្វើតេស្តគុណភាពជ័រប្រៀបធៀបអន្តរមន្ទីរពិសោធន៍ជាមួយ IRA
- ១.១៦.១៤ រៀបចំនិងធ្វើតេស្តប្រៀបធៀបមន្ទីរពិសោធន៍ក្នុងស្រុក
- ១.១៦.១៥ ចុះត្រួតពិនិត្យរោងចក្រ CSR និង Lab CSR។

២៥- ឆ្នាំ២០១៦ ជាឆ្នាំមួយដែលអនុវត្តប្រព័ន្ធថវិកាថ្មី គឺការផ្តោតលើលទ្ធផលឬសមិទ្ធកម្ម និងវិមជ្ឈការ ជាពិសេសលទ្ធផលដែលអនុវត្តបាន ត្រូវវាស់វែងផ្អែកលើគោលដៅសូចនាករ។ សមិទ្ធផលផ្នែកកៅស៊ូដែលសម្រេចបានតាមបណ្តាចង្កោមសកម្មភាពនៃអនុកម្មវិធីនីមួយៗរបស់ថវិកាកម្មវិធីក្នុងឆ្នាំនេះ អាចវាយតម្លៃបានថា មានការរីកចម្រើនគួរជាទីមោទកភាព (ឧបសម្ព័ន្ធទី២)។

២៦- បានរៀបចំកសាងគម្រោងផែនការថវិកាកម្មវិធីឆ្នាំ២០១៧ សម្រាប់អគ្គនាយកដ្ឋានកៅស៊ូទាន់ពេលវេលា និងទទួលបានការអនុម័តយល់ព្រមផ្តល់ថវិកាសម្រាប់គម្រោងថវិកាកម្មវិធី ពីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុដែលមានអនុកម្មវិធីចំនួន៥ និងចង្កោមសកម្មភាពចំនួន១៤ ដែលក្នុងនោះ ចង្កោមសកម្មភាព១ គឺជាការចំណាយលើបន្ទុកបុគ្គលិក (ឧបសម្ព័ន្ធទី៣)។

## ២.២.២ ការងារហិរញ្ញវត្ថុ

២៧- រៀបចំគម្រោងចំណាយថវិកាកម្មវិធី និងស្នើសុំគោលការណ៍ចំណាយថវិការដ្ឋទេយ្យបុរេប្រទានសម្រាប់អនុវត្តក្នុងឆ្នាំ។ រៀបចំផែនការលទ្ធកម្មប្រចាំឆ្នាំ និងស្នើសុំគោលការណ៍ធានាចំណាយថវិកាលើការងារលទ្ធកម្មទូទៅ ប្រេងឥន្ធនៈ សម្ភារការិយាល័យ សង្ហារឹម ឧបករណ៍បច្ចេកទេស សំលៀកបំពាក់ស្ម័យការពារ ជួសជុលរថយន្ត និងជួលជុលអាគារ ធ្វើការដេញថ្លៃ និងធ្វើការប្រគល់ ទទួលបានរួចក្នុងឆ្នាំ។ រៀបចំសក្ខីប័ត្រ បញ្ចប់លើការងារទូទាត់ថវិកាកម្មវិធី ទាំង៤ជំហ៊ាន។ រៀបចំការចុះបញ្ជីសារពើភ័ណ្ឌកើន ថយ ទ្រព្យសម្បត្តិរដ្ឋរបស់អគ្គនាយក-ដ្ឋានកៅស៊ូ។

២៨- ធ្វើការជាប្រចាំជាមួយនាយកដ្ឋានគណនេយ្យ និងហិរញ្ញវត្ថុ និងនាយកដ្ឋានផែនការ ស្ថិតិ នៃក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ក្នុងការរៀបចំចំណាយថវិកានិងអនុវត្តគម្រោងផែនការ រៀបចំឯកសារនានាពាក់ព័ន្ធនឹងការចុះបញ្ជីសារពើភណ្ឌទ្រព្យសម្បត្តិរដ្ឋរបស់អគ្គនាយកដ្ឋានកៅស៊ូ។

តារាងទី២ ការប្រៀបធៀបរវាងថវិកាអនុម័តឆ្នាំ២០១៥/២០១៦

| ជំពូក | ចំណាត់ថ្នាក់ចំណាយ | ២០១៥ | ២០១៦ | % |
|---|---|---|---|---|
| ៦០ | ការទិញ | ៤៦៤ ៦០០ ០០០ | ៣៧៩ ៧០០ ០០០ | ៨១,៧៣ |
| ៦១ | សេវាខាងក្រៅ | ១ ១០៩ ១០០ ០០០ | ១ ៤០៨ ៥០០ ០០០ | ១២៦,៩៩ |
| ៦៣ | ពន្ធនិងអាករ | ៧ ៩០០ ០០០ | ៧ ០០០ ០០០ | ៨៦,៦១ |
| ៦៤ | បន្ទុកបុគ្គលិក | ១ ០៤៩ ៧០០ ០០០ | ១ ០៤២ ៨០០ ០០០ | ៩៩,៣៤ |
| ៦៥ | ឧបត្ថម្ភធននិងជំនួយសង្គម | ៣០ ០០០ ០០០ | ៣០ ០០០ ០០០ | ១០០,០០ |
| | សរុប | **២ ៦៦១ ៣០០ ០០០** | **២ ៨៦៨ ០០០ ០០០** | **១០៧,៧៧** |

២៩- ការអនុវត្តថវិកាប្រចាំឆ្នាំ (លើកលែងថវិកាស្រាវជ្រាវរបស់វិទ្យាស្ថានស្រាវជ្រាវកៅស៊ូកម្ពុជា) សម្រាប់ការអភិវឌ្ឍដំណាំកៅស៊ូក្នុងរយៈពេល៦ឆ្នាំនេះ គិតពីឆ្នាំ២០១០ ដល់ឆ្នាំ២០១៦ មានការកើនឡើងជាលំដាប់ក្នុងកម្រិតប្រមាណ១១,៦១% ក្នុង១ឆ្នាំ។ បើធៀបនឹងថវិកាអនុម័ត ការអនុវត្តថវិកាក្នុងរយៈពេល៦ឆ្នាំសម្រេចបានពី៩៦,៧៨% ទៅ១០៧,៧៨%។ ការចំណាយខ្ពស់ដល់ទៅ១០៧,៧៨%នេះ បណ្ដាលមកពីមានការចំណាយលើសនៃបន្ទុកបុគ្គលិក ប៉ុន្តែជារួមកម្រិតអនុវត្តផែនការថវិកាទាំងនេះ អាចចាត់ទុកថាបានអនុវត្តក្នុងកម្រិតល្អ។

ក្រាហ្វិកទី១ ការប្រៀបធៀបថវិកាអនុវត្តនិងថវិកាអនុម័តឆ្នាំពី២០១០-២០១៦




៣០- ការប្រមូលចំណូលឆ្នាំ២០១៦ អនុវត្តបានចំនួន១ ៤៤១ ៦៩០ ៨៨៣រៀល (៣៦០ ៤២៣ដុល្លារអាម៉េរិក) ក្នុងនោះរួមមាន៖ ការជួលដីក្រុមហ៊ុនទាំង០៧មានចំនួន១ ២៥៤ ០៤០ ៤៦១,៣៣រៀល (៣១៣ ៥១០ ដុល្លារអាម៉េរិក), ការជួលដីសហគ្រាសសាធារណៈថ្នាក់រដ្ឋបាលកណ្ដាល (ចម្ការកៅស៊ូឡាបានសៀក ខេត្តរតនគិរី) ចំនួន៩៦ ៣៨០ ៩៤២រៀល (២៤ ០៩៥ដុល្លារអាម៉េរិក) និងការជួលអចលនវត្ថុ (អសង្ហារឹម) ក្រុមហ៊ុននីហរ័ណ អាហរ័ណកៅស៊ូចំនួន៩១ ២៦៩ ៤៨០រៀល (២២ ៨២៧ដុល្លារអាម៉េរិក)។ បើធៀបនឹងគោលដៅចំនួន១ ៤១០ ១៩៨ ៤៩៩រៀល (៣៥២ ៥៥០ដុល្លារអាម៉េរិក) មានការកើនឡើងចំនួន៣១ ៤៩២ ៣៨៤ រៀល (៧ ៨៧៣ដុល្លារអាម៉េរិក) ស្មើនឹង២,២៣%។ ការកើនឡើងនេះដោយសារ ការផាកពិន័យទៅលើក្រុមហ៊ុនមួយចំនួនដែលយឺតយ៉ាវក្នុងការបង់ប្រាក់ឈ្នួល។ ទន្ទឹមនឹងនេះនៅឆ្នាំ២០១៦ អគ្គនាយកដ្ឋានកៅស៊ូក៏បានប្រមូលចំណូលការជួលដី និងប្រាក់ពិន័យដែលក្រុមហ៊ុនមិនបានបង់ក្នុងឆ្នាំ២០១៥ ចំនួន៣៥១ ៨៤៧ ៥៦១ រៀល។

ក្រាហ្វិកទី២ ការប្រមូលចំណូលរបស់អគ្គនាយកដ្ឋានកៅស៊ូឆ្នាំ២០១៦




៣១- រៀបចំឯកសារនានាពាក់ព័ន្ធនឹងការចុះបញ្ជីសារពើភ័ណ្ឌទ្រព្យសម្បត្តិរដ្ឋ និងគម្រោងអភិវឌ្ឍន៍កៅស៊ូគ្រួសារ (AFD) របស់អគ្គនាយកដ្ឋានកៅស៊ូ។

៣២- សហការជាមួយគណៈប្រតិភូអធិការកិច្ចហិរញ្ញវត្ថុ (ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ) ពិនិត្យការគ្រប់គ្រងចំណូលចំណាយថវិការដ្ឋ ការគ្រប់គ្រងចំណូលមិនមែនសារពើពន្ធ ការគ្រប់គ្រងទ្រព្យសម្បត្តិរដ្ឋ និងកាតព្វកិច្ចត្រូវបង់ចំណូលចូលថវិការដ្ឋក្នុងការិយបរិច្ឆេទឆ្នាំ២០១៥។ តាមដានការចំណាយថវិកាកម្មវិធី ដែលបានអនុវត្តកន្លងមក។

៣៣- ចូលរួមសិក្ខាសាលា និងវគ្គបណ្តុះបណ្តាលដូចខាងក្រោម៖

១. សិក្ខាសាលាស្តីពីវឌ្ឍនភាពការអនុវត្តថវិកាកម្មវិធីពេញលេញរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ នៅខេត្តសៀមរាប។

២. វគ្គបណ្តុះបណ្តាលស្តីពីគោលការណ៍ស្តីពីការណែនាំស្តីពីនីតិវិធីអនុវត្តថវិកាកម្មវិធី នៅសណ្ឋាគារភ្នំពេញ។

៣. កិច្ចប្រជុំស្តីពីនីតិវិធីអនុវត្តថវិកាកម្មវិធី នៅសណ្ឋាគារឡឺរ៉ូយ៉ាល់។

៤. សិក្ខាសាលាស្តីពីការផ្សព្វផ្សាយគោលការណ៍ណែនាំស្តីពីការអនុវត្តថវិកាកម្មវិធី របស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ នៅខេត្តកែប។

ការងាររបស់នាយកដ្ឋានផែនការ ហិរញ្ញវត្ថុ និងស្ថិតិមានលម្អិតក្នុងបទបង្ហាញទី៥។

## ២.៣ ការងារអភិវឌ្ឍន៍

### ២.៣.១ ស្ថិតិផ្ទៃដី ផលិតផល និងការនាំចេញកៅស៊ូធម្មជាតិ

៣៤- នៅឆ្នាំ២០១៦នេះ ផ្ទៃដីកៅស៊ូកម្ពុជាសរុបចំនួន ៤៣២ ៧៣៥ហិកតា បើធៀបទៅនឹងឆ្នាំ២០១៥ មានចំនួន ៣៨៨ ៩៥៥ហិកតា កើនឡើងចំនួន៤៣ ៧៨០ហិកតា ស្មើ១១,២៥%។ ផ្ទៃដីកៅស៊ូទាំងនេះត្រូវបានបែងចែកជា០២ផ្នែកគឺៈ ក្រុមហ៊ុនកៅស៊ូកសិឧស្សាហកម្ម (អតីតចម្ការកៅស៊ូរដ្ឋ ផ្ទៃដីវិទ្យាស្ថានស្រាវជ្រាវកៅស៊ូកម្ពុជា និងផ្ទៃដីក្រុមហ៊ុនសម្បទានដីសេដ្ឋកិច្ច) សរុបមានចំនួន២៧៨ ២៨១ហិកតា ស្មើ៦៤,៣១% និងកៅស៊ូគ្រួសារមានចំនួន១៥៤ ៤៥៤ហិកតា ស្មើ៣៥,៦៩% នៃផ្ទៃដីកៅស៊ូសរុប (តារាងទី៣ ក្រាហ្វិកទី៣ និងក្រាហ្វិកទី៤)។

តារាងទី៣ ស្ថិតិផ្ទៃដីដំណាំកៅស៊ូឆ្នាំ២០១៦ (ហិកតា)

| ប្រភេទចម្ការកៅស៊ូ | ចៀរជ័រ | ថែទាំ | សរុប | ភាគរយ |
|---|---|---|---|---|
| **១.ចម្ការកៅស៊ូកសិឧស្សាហកម្ម** | ៤០ ៦៦៥ | ២៣៧ ៦១៦ | ២៧៨ ២៨១ | ៦៤,៣១% |
| -អតីតចម្ការកៅស៊ូរដ្ឋនិងវ.ស.ក.ក. | ៣១ ៧០៥ | ២២ ៨១៨ | ៥៤ ៥២៣ | ១២,៦០% |
| -ចម្ការកៅស៊ូសម្បទានដីសេដ្ឋកិច្ច | ៨ ៩៦០ | ២១៤ ៧៩៨ | ២២៣ ៧៥៨ | ៥១,៧១% |
| **២. ចម្ការកៅស៊ូគ្រួសារ** | ៨៦ ៣៣១ | ៦៨ ១២៣ | ១៥៤ ៤៥៤ | ៣៥,៦៩% |
| សរុប | **១២៦ ៩៩៦** | **៣០៥ ៧៣៩** | **៤៣២ ៧៣៥** | **១០០%** |

សម្គាល់ៈ វ.ស.ក.ក.ៈ វិទ្យាស្ថានស្រាវជ្រាវកៅស៊ូកម្ពុជា

ក្រាហ្វិកទី៣ អត្រាភាគរយនៃប្រភេទផ្ទៃដីចម្ការកៅស៊ូ២០១៦



ក្រាហ្វិកទី៤ ទំហំប្រភេទផ្ទៃដីដំណាំកៅស៊ូឆ្នាំ២០១២-២០១៦ (ហិកតា)




៣៥- ឆ្នាំ២០១៦នេះ ផ្ទៃដីកៅស៊ូចៀរអនុវត្តបានចំនួន១២៦ ៩៩៦ហ.ត. ធៀបនឹងផ្ទៃដីកៅស៊ូចៀរឆ្នាំ២០១៥ មានចំនួន១១១ ២៣២ហ.ត. កើនឡើងចំនួន១៥ ៧៦៤ហ.ត. ស្មើ១៤,១៧% (ក្រាហ្វិកទី៥)។ ផលិតផលកៅស៊ូសម្រេចបានចំនួន១៤៥ ២០០តោន ធៀបនឹងឆ្នាំ២០១៥ចំនួន១២៦ ៨៦១តោន កើនឡើងចំនួន១៨ ៣៣៩តោន ស្មើនឹង១៤,៤៦%។ ទិន្នផលមធ្យមចំនួន១ ១៤៣គ.ក្រ./ហ.ត. ធៀបនឹងឆ្នាំ២០១៥ ដែលមានចំនួន១ ១៤១គ.ក្រ./ហ.ត. គឺកើនឡើង០,១៧% (ឧបសម្ព័ន្ធទី៤)។ ចំណែកស្ថិតិផ្ទៃដីកៅស៊ូលម្អិតមានបង្ហាញជូនក្នុងឧបសម្ព័ន្ធទី៥ ទី៦ ទី៧ ទី៨ ទី៩ ទី១០ និងទី១១។
ការងាររបស់នាយកដ្ឋានអភិវឌ្ឍន៍កៅស៊ូមានលម្អិតក្នុងបទបង្ហាញពី១។

ក្រាហ្វិកទី៥ ផ្ទៃដីកៅស៊ូចៀរជ័រ ថែទាំ និងសរុប ឆ្នាំ២០១២-២០១៦



៣៦- ការនាំចេញកៅស៊ូឆ្នាំ២០១៦ សម្រេចបានចំនួន១៤៥ ១០០តោន ស្មើនឹងទឹកប្រាក់ចំនួន១៨៧ ១៦៤ ៥៥១ ដុល្លារអាម៉េរិក បើធៀបនឹងឆ្នាំ២០១៥ ដែលការនាំចេញមានចំនួន១២៨ ០៤៧តោន ស្មើនឹងទឹកប្រាក់ចំនួន ១៥៤ ០០១ ១៥១ដុល្លារអាម៉េរិក គឺផលិតផលកៅស៊ូនាំចេញកើនឡើងចំនួន១៧ ០៥៣តោន ស្មើនឹង ១៣,៣២%។ ទឹកប្រាក់ចំណូលកើនឡើងប្រមាណ ២១,៥៣% ដោយសារស្ថានភាពកៅស៊ូ នៅលើទីផ្សារ អន្តរជាតិបានបន្តធ្លាក់ចុះយ៉ាងខ្លាំងក្នុងឆ្នាំ២០១៥ និងត្រឹមត្រីមាសទី៣ឆ្នាំ២០១៦ ដែលមិនធ្លាប់ មានក្នុង រយៈពេល៩ឆ្នាំកន្លងមកនេះ។ តម្លៃកៅស៊ូនាំចេញជាមធ្យម១ ២៩០ដុល្លារអាម៉េរិក ក្នុងមួយតោន បើធៀប នឹងឆ្នាំ២០១៥ ដែលតម្លៃមធ្យម ១ ២០៣ដុល្លារអាម៉េរិកក្នុងមួយតោន កើនឡើង៨៧ដុល្លារអាម៉េរិក ក្នុងមួយតោន ស្មើនឹង៧,២៣%។

ការងាររបស់នាយកដ្ឋានទីផ្សារ និងសហប្រតិបត្តិការអន្តរជាតិមានលម្អិតនៅក្នុងបទបង្ហាញទី២។

ក្រាហ្វិកទី៦ ផលិតកម្មនិងការនាំចេញកៅស៊ូធម្មជាតិឆ្នាំ២០១២-២០១៦




## ២.៣.២ ស្ថិតិរោងចក្រ និងសិប្បកម្មកែច្នៃផលិតផលកៅស៊ូធម្មជាតិ

៣៧- នៅក្នុងឆ្នាំ២០១៦នេះ រោងចក្រ សិប្បកម្មកែច្នៃផលិតផលកៅស៊ូមានសរុបចំនួន១២៦កន្លែង ក្នុងខេត្តចំនួន ១១ (កំពង់ចាម ត្បូងឃ្មុំ កំពង់ធំ មណ្ឌលគិរី ក្រចេះ ស្ទឹងត្រែង រតនគិរី ឧត្តរមានជ័យ ព្រះវិហារ ព្រះសីហនុ និងប៉ៃលិន) គឺកើនឡើងចំនួន៦កន្លែង ស្មើនឹង៥% បើប្រៀបធៀបទៅនឹងឆ្នាំ២០១៥ ដែលមានតែ១២០កន្លែង។ ក្នុងចំណោមរោងចក្រ សិប្បកម្មចំនួន១២៦កន្លែង មានរោងចក្រកែច្នៃកៅស៊ូដុំ (TSR: Technically Specified Rubber) ចំនួន៣៧កន្លែង សិប្បកម្មកែច្នៃកៅស៊ូសន្លឹកក្រឡាសម្ងួតដោយផ្សែង (RSS: Ribbed Smoked Sheet) និងសិប្បកម្មកែច្នៃកៅស៊ូសន្លឹកសម្ងួតដោយខ្យល់ក្តៅគ្មានផ្សែង (ADS: Air-Dried Sheet) មានចំនួន ៨៥កន្លែង និងរោងចក្រកែច្នៃឈើកៅស៊ូចំនួន០៤កន្លែង (ឧបសម្ព័ន្ធទី១២)។

ការងាររបស់នាយកដ្ឋានកែច្នៃផលិតផលកៅស៊ូមានលម្អិតក្នុងបទបង្ហាញទី៣។

## ២.៣.៣ ការងារផ្សព្វផ្សាយនិងបណ្តុះបណ្តាល

៣៨- ការងារដែលបាននិងកំពុងអនុវត្តលើការបណ្តុះបណ្តាលជំនាញបច្ចេកទេសរួមមាន៖

១. ការបណ្តុះបណ្តាលជំនាញចៀរជ័រដល់កសិករកៅស៊ូគ្រួសារ
ចុះបើកវគ្គបណ្តុះបណ្តាលការបើកមុខចៀរដំបូង និងបច្ចេកទេសចៀរជ័រកៅស៊ូ ដល់កសិករកៅស៊ូគ្រួសារ នៅខេត្តគោលដៅគឺ បាត់ដំបង ប៉ៃលិន រតនគិរី ស្ទឹងត្រែង និងព្រះវិហារ បានចំនួន៥វគ្គ ដោយមានកសិករចូលរួមសរុប២៣៨នាក់ គម្រោងសរុប២២៥នាក់ (៤៥នាក់/វគ្គ)។ វគ្គបណ្តុះបណ្តាលនេះ កសិករបានទទួលចំណេះដឹងទាំងមេរៀនទ្រឹស្តី និងការអនុវត្តចៀរជ័រលើដើមកៅស៊ូជាក់ស្តែងនៅនឹងកន្លែង សំដៅឱ្យការប្រមូលផលរបស់ពួកគាត់មានរយៈពេលយូរអង្វែង ទទួលបានទិន្នផលខ្ពស់ និងត្រឹមត្រូវតាមបទដ្ឋានបច្ចេកទេសចៀរជ័រ។

២. ការងារផ្សព្វផ្សាយបច្ចេកទេសដំណាំកៅស៊ូដល់កសិករកៅស៊ូគ្រួសារ
ចុះបើកវគ្គផ្សព្វផ្សាយបច្ចេកទេសដំណាំកៅស៊ូដល់កសិករកៅស៊ូគ្រួសារ នៅខេត្តគោលដៅ ទាំង ៨ គឺ បាត់ដំបង ប៉ៃលិន មណ្ឌលគិរី រតនគិរី ព្រះវិហារ កំពង់ធំ ត្បូងឃ្មុំ និងកំពង់ចាម ដោយមានកសិករចូលរួមសរុប៤៨២នាក់ គម្រោងសរុប៤៨០នាក់ (៦០នាក់/វគ្គ)។ កសិករដែលបានចូលរួមទទួលបានឯកសារមេរៀន និងស្តាប់ការធ្វើបទបង្ហាញរបស់វាគ្មិន និងឆ្លើយបំភ្លឺរាល់ចម្ងល់និងសំណួរនានាតាមមេរៀននីមួយៗ ដើម្បីឱ្យកសិករអ្នកដាំកៅស៊ូ ដែលមានបំណងដាំកៅស៊ូទទួលបានចំណេះដឹងនេះយកទៅអនុវត្តលើការជ្រើសរើសពូជ ការងារដាំដុះ និងថែទាំ ការព្យាបាលជម្ងឺ និងការបើកមុខចៀរដំបូងឱ្យបានត្រឹមត្រូវតាមលក្ខណៈបច្ចេកទេស សំដៅឱ្យទទួលបានលទ្ធផលល្អនៅថ្ងៃខាងមុខ។

៣. ការងារបណ្តុះបណ្តាលបច្ចេកទេសដំណាំកៅស៊ូដល់មន្ត្រីបង្គោល
ចុះបើកវគ្គបណ្តុះបណ្តាលបច្ចេកទេសដំណាំកៅស៊ូបានចំនួន០៥វគ្គ ដល់មន្ត្រីកសិកម្ម ខេត្តគោលដៅរួមមាន ខេត្តមណ្ឌលគិរី រតនគិរី បាត់ដំបង ប៉ៃលិន និងព្រះសីហនុ ដោយមានមន្ត្រីចូលរួមសរុបចំនួន១១២នាក់ គម្រោងសរុប១០០នាក់ (២០នាក់/វគ្គ)។ វគ្គបណ្តុះបណ្តាលនេះ សំដៅបង្កើនសមត្ថភាពយល់ដឹងដល់មន្ត្រីកសិកម្មខេត្តឱ្យក្លាយជាមន្ត្រីបង្គោលលើជំនាញកៅស៊ូ និងក្លាយជាអ្នកផ្សព្វផ្សាយបន្តដល់អ្នកដាំកៅស៊ូ ជាពិសេសកសិករកៅស៊ូគ្រួសារ ដើម្បីជំរុញអភិវឌ្ឍន៍ដំណាំកៅស៊ូប្រកបដោយប្រសិទ្ធ-ភាពសេដ្ឋកិច្ចខ្ពស់ និងចីរភាព។

៤. ការងារពង្រឹង និងចងក្រងសហគមន៍កសិករកៅស៊ូគ្រួសារ
ចងក្រងបង្កើតសហគមន៍កសិករកៅស៊ូគ្រួសារនៅខេត្តគោលដៅចំនួន០៣គឺ ព្រះវិហារ ត្បូងឃ្មុំ និងក្រចេះ បានចំនួន០៣សហគមន៍ ដែលក្បាលម៉ាស៊ីនដឹកនាំរបស់សហគមន៍ មានក្រុមប្រឹក្សាភិបាលចំនួន០៧រូប និងគណៈកម្មាធិការត្រួតពិនិត្យចំនួន០៥រូប។ ការបង្កើតសហគមន៍នេះ គឺដើម្បីលើកកម្ពស់អំណាចចរចាទីផ្សាររបស់ប្រជាកសិករ កាត់បន្ថយថ្លៃដើមផលិតកម្មកសិកម្មរបស់ប្រជាកសិករជាសមាជិកសហគមន៍ផលិតកសិផល ឬផ្តល់សេវាកម្មណាដែលកសិករម្នាក់ៗមិនអាចធ្វើបាន ទទួលបានព័ត៌មានទីផ្សារ និងពង្រីកឱកាសទីផ្សារកសិផលរបស់កសិករ លើកកម្ពស់គុណភាពកសិផល ឬផលិតផលរបស់កសិករ និងបង្កើនប្រាក់ចំណូលគ្រួសាររបស់កសិករជាសមាជិកសហគមន៍។

៥. ការងារផ្សព្វផ្សាយបច្ចេកទេសកែច្នៃដល់ប្រតិបត្តិករកៅស៊ូ
ចុះបើកវគ្គផ្សព្វផ្សាយបច្ចេកទេសកែច្នៃដល់ប្រតិបត្តិករកៅស៊ូ ចំនួន០២លើក នៅខេត្តគោលដៅចំនួន០២គឺ កំពង់ចាម និងក្រចេះដល់ម្ចាស់រោងចក្រ សិប្បកម្មកែច្នៃជ័រកៅស៊ូ មកពីខេត្តគោលដៅចំនួន០៩

គឺកំពង់ចាម ត្បូងឃ្មុំ កំពង់ធំ ព្រះវិហារ ក្រចេះ ស្ទឹងត្រែង រតនគិរី មណ្ឌលគិរី និងឧត្តរមានជ័យ ដោយមានម្ចាស់រោងចក្រ សិប្បកម្មចូលរួមសរុបចំនួន១២០នាក់។

៦. ការងារផ្សព្វផ្សាយនិងបណ្តុះបណ្តាលបច្ចេកទេសកែច្នៃកៅស៊ូសន្លឹកសម្ងួតដោយខ្យល់ (Unsmoked sheet : USS) ដល់សហគមន៍កៅស៊ូគ្រួសារចុះបើកវគ្គផ្សព្វផ្សព្វផ្សាយ និងបណ្តុះបណ្តាលបច្ចេកទេសកែច្នៃកៅស៊ូសន្លឹកសម្ងួតដោយខ្យល់ (Unsmoked sheet : USS) ដល់សហគមន៍កៅស៊ូគ្រួសារ ចំនួន ០៥លើក នៅខេត្តគោលដៅចំនួន០៤ គឺកំពង់ចាម ត្បូងឃ្មុំ ស្ទឹងត្រែង និងក្រចេះ។ ដោយមានម្ចាស់កៅស៊ូគ្រួសារចូលរួមសរុបចំនួន២៥០នាក់។

៧. ផ្សព្វផ្សាយលិខិតបទដ្ឋានគតិយុត្តដែលពាក់ព័ន្ធដល់ផ្នែកកៅស៊ូ នៅស្រុកគោលដៅចំនួន១០ ក្នុង០៧ខេត្តគឺ ខេត្តកំពង់ចាម (០២ស្រុក) កំពង់ធំ ត្បូងឃ្មុំ (០២ស្រុក) រតនគិរី (០២ស្រុក) ក្រចេះ បាត់ដំបង និងសៀមរាប ដោយមានប្រតិបត្តិករកៅស៊ូចូលរួមសរុប៤០០នាក់។

៨. បណ្តុះបណ្តាលសមត្ថភាពជំនាញដល់ប្រតិបត្តិករកៅស៊ូចំនួន០១វគ្គ រយៈពេល០៣ថ្ងៃ ដោយមានប្រតិបត្តិករកៅស៊ូចូលរួមសរុប៣៥នាក់។

៩. បើកបណ្តុះបណ្តាលស្តីពីវិធីសាស្ត្រព្យាករណ៍ការផ្គត់ផ្គង់កៅស៊ូធម្មជាតិ ដល់មន្ត្រីរាជការនិងនិយោជិតចម្ការកៅស៊ូកសិឧស្សាហកម្ម ចំនួន២លើក ដោយមានអ្នកចូលរួមសរុប៦៣នាក់។

១០. បើកបណ្តុះបណ្តាលស្តីពីការរៀបចំថវិកាកម្មវិធីដល់មន្ត្រីរាជការ ចំនួន០១លើក ដោយមានអ្នកចូលរួមសរុប២៥នាក់។

១១. ការរៀបចំវគ្គបណ្តុះបណ្តាលកសិករកៅស៊ូគ្រួសារចំនួន០៦វគ្គ រួមមាន ៖ (១) បច្ចេកទេសដាំដុះ និងថែទាំកូនកៅស៊ូ (២) ការគ្រប់គ្រងច្បារពូជនិងថ្នាលបណ្តុះកូនកៅស៊ូ (៣) បច្ចេកទេសប្រមូលផលទឹកជ័រ និងការបើកមុខចៀរកៅស៊ូថ្មីចំនួន០២វគ្គ (៤) ការគ្រប់គ្រងសមាសភាពចង្រៃនិងជំងឺកៅស៊ូ (៥) បច្ចេកទេសនៃការធ្វើអត្តសញ្ញាណកម្មក្លូនកៅស៊ូ ដោយមានកសិករអញ្ជើញចូលរួមវគ្គទាំង០៦ជាសរុបមានចំនួន៣៧៥នាក់

១២. ការបញ្ជូនមន្ត្រីចំនួន១០រូបឱ្យជួយបណ្តុះបណ្តាលនិស្សិតនៅសាកលវិទ្យាល័យភូមិន្ទកសិកម្ម និងសាលាជាតិកសិកម្មកំពង់ចាម

១៣. ដឹកនាំដល់និស្សិត ក្នុងការសរសេរសារណាបញ្ចប់ការសិក្សាថ្នាក់បរិញ្ញាបត្រចំនួន១៣រូប មកពីសាកលវិទ្យាល័យភូមិន្ទកសិកម្ម សាកលវិទ្យាល័យស្វាយរៀង សាលាជាតិកសិកម្មកំពង់ចាម និងវិទ្យាស្ថានបច្ចេកទេសកម្ពុជា

១៤. ការផ្ទេរបច្ចេកវិទ្យាដល់និស្សិតប្រមាណ១០០នាក់ ដែលបានធ្វើទស្សនកិច្ចសិក្សានៅទីវាលនៃស្ថានីយ៍អនុវត្ត (វសកក) ក្នុងនោះមាននិស្សិតមកពីសាកលវិទ្យាល័យភូមិន្ទកសិកម្ម និស្សិតសាលាជាតិកសិកម្មកំពង់ចាម និងនិស្សិតមកពីសាកលវិទ្យាល័យស្វាយរៀង។

## ២.៤ ការងារពិសោធន៍ និងស្រាវជ្រាវ

៣៩- វិទ្យាស្ថានស្រាវជ្រាវកៅស៊ូកម្ពុជា (វសកក) មានភារកិច្ចដឹកនាំ និងសម្រេចរាល់សកម្មភាពស្រាវជ្រាវនិងពិសោធន៍សំដៅជំរុញការអភិវឌ្ឍលើគ្រប់ផ្នែកនៃដំណាំកៅស៊ូ ចូលរួមក្នុងសកម្មភាពជំរុញផ្នែកបច្ចេកទេសសុវត្ថិកម្មពូជកៅស៊ូ គុណភាពជ័រកៅស៊ូ និងតម្លៃផលិតកម្ម។ ***វសកក*** បានអនុវត្ត និងបន្តការងារស្រាវជ្រាវ

ហើយនិងតាមដានទិន្នន័យចម្ការពិសោធន៍ទាំងនៅក្នុងស្ថានីយ៍ទាំងនៅតាមបណ្ដាក្រុមហ៊ុនចម្ការកៅស៊ូ ដែលជាសរុបមានចំនួន**៦០**ពិសោធន៍។ ដោយឡែកមន្ទីរពិសោធន៍ជាតិយថាប្រភេទបានជួយបណ្ដុះបណ្ដាលដល់បុគ្គលិកមន្ទីរពិសោធន៍ នៃបណ្ដារោងចក្រក្រុមហ៊ុន ចម្ការកៅស៊ូនានា ក្នុងការកែច្នៃជ័រ និងជួយមន្ទីរពិសោធន៍មូលដ្ឋានក្នុងការវិភាគគុណភាពជ័រ ដើម្បីអភិវឌ្ឍផលិតកម្ម និងឈានដល់ការសុំសិទ្ធិទទួលស្គាល់ពីមន្ទីរពិសោធន៍ជាតិយថាប្រភេទនៃ ***វសកក*** ក្នុងការចេញ **វិញ្ញាបនបត្រ** បញ្ជាក់គុណភាពកៅស៊ូ។ ***វសកក*** បានផ្ទេរនូវបច្ចេកវិទ្យា ដោយការសម្របសម្រួលឱ្យនិស្សិតធ្វើទស្សនកិច្ចសិក្សាចម្ការពិសោធន៍និងការដឹកនាំសារណាបញ្ចប់ការសិក្សា ថ្នាក់បរិញ្ញបត្ររបស់និស្សិត។ ក្នុងការអភិវឌ្ឍក្លូនកៅស៊ូ ***វសកក*** បានចូលរួមក្នុងកម្មវិធីប្ដូរក្លូនពហុភាគីរវាងប្រទេសជាសមាជិក IRRDB ក្នុងនោះ ***វសកក*** បានផ្ញើមែកពូជ CMS ចំនួន០៥ក្លូនទៅឱ្យប្រទេសឥណ្ឌា និងថៃចំនួន៥០ម៉ែត្រ និងទទួលបានមែកពូជពីប្រទេសឥណ្ឌា និងថៃចំនួន៥០ម៉ែត្រ ហើយនិងទទួលបានមែកពូជ CMS ០៣ក្លូនបន្ថែមទៀតពី CIRAD តាមរយៈប្រទេស**ហ្គាណា**។ ក្នុងការពង្រឹងនូវគុណភាព និងសមត្ថភាពមន្ត្រីស្រាវជ្រាវ និងប្រតិបត្តិករកៅស៊ូក្នុងឧស្សាហកម្មកៅស៊ូធម្មជាតិ ***វសកក*** បានរៀបចំសិក្ខាសាលា វគ្គបណ្ដុះបណ្ដាលខ្លីផ្សេងៗ ហើយនិងការបញ្ជូនមន្ត្រីឱ្យទៅចូលរួមសិក្ខាសាលាសន្និសីទ នៅក្នុងនិងក្រៅប្រទេសជាច្រើនលើក។ នៅឆ្នាំ២០១៦នេះ ***វសកក*** មានកិត្តិយស ធ្វើជាម្ចាស់ផ្ទះក្នុងការរៀបចំសន្និសីទ និងកិច្ចប្រជុំប្រចាំឆ្នាំនៃក្រុមប្រឹក្សាស្រាវជ្រាវ និងអភិវឌ្ឍកៅស៊ូអន្តរជាតិ ២០១៦ (IRRDB International Rubber Conference and Annual Meeting 2016) នៅខេត្តសៀមរាប ចាប់ពីថ្ងៃទី២១-២៥ ខែវិច្ឆិកា ឆ្នាំ២០១៦ ក្រោមប្រធានបទ "**និរន្តរភាព នៃឧស្សាហកម្មកៅស៊ូធម្មជាតិៈ បញ្ហាការប្រឈម និងកាលានុវត្តភាព**" ។

៤០- ការងារដែលបាននិងកំពុងអនុវត្តលើការស្រាវជ្រាវផ្នែកក្សេត្រសាស្ត្រៈ

- ការស្រង់ទិន្នន័យបញ្ចូលនិងវិភាគទិន្នន័យគ្រប់ចម្ការពិសោធន៍ចំនួន៦០ ក្នុងបរិវេណស្ថានីយ៍អនុវត្តនិងនៅតាមបណ្ដាក្រុមហ៊ុន
- ការរៀបចំរបាយការណ៍បច្ចេកទេសប្រចាំឆ្នាំ
- ការធ្វើតេស្តចៀរជ័រវាយតម្លៃទិន្នផលចម្ការពិសោធន៍ជម្រើសពូជបឋម (SET)
- ការដាំជួសកូនកៅស៊ូនៅចម្ការពិសោធន៍ក្លូនទ្រង់ទ្រាយធំចំនួនពីរ (PVAA01, PVAA02) នៅក្រុមហ៊ុនទ្រីភាព បឹងទន្លេម្រេច ក្នុងស្រុករវៀង ខេត្តព្រះវិហារ បានចំនួន ១៨៧៥ ដើម
- ការដាំជួសកូនកៅស៊ូនៅចម្ការពិសោធន៍ក្នុងស្ថានីយ៍ចំនួន៣១,៥ហ.ត
- ការស្រង់ទិន្នន័យជំងឺ Oidium នៅតាមបណ្ដាចម្ការពិសោធន៍ក្លូន
- ការរៀបចំថ្នាលបណ្ដុះកូនកៅស៊ូថ្មីសម្រាប់ឆ្នាំ២០១៦-២០១៧ ចំនួន០,៣៥ហ.ត
- ការរៀបចំ និងដាំដុះចម្ការពិសោធន៍ថ្មីចំនួន១៩ហ.ត
- ការរៀបចំចម្ការពិសោធន៍ថ្មី០១នៅចម្ការកៅស៊ូក្រែក
- ការបាញ់ថ្នាំព្យាបាលជំងឺផ្កាកូលាប Pink Disease នៅតាមប្រគៀបមែកកៅស៊ូចាប់ពីកៅស៊ូ អាយុ០៣ឆ្នាំ រហូតដល់អាជីវកម្មបានចំនួន០៤ជុំ លើផ្ទៃដី១៥០ហ.ត
- ការថែទាំកូនកៅស៊ូចំនួន១៣៧,៥ ហ.ត
- ការងារគ្របគល់កូនកៅស៊ូចម្ការពិសោធន៍ថ្មីចំនួន១៩ហ.ត
- ការថែទាំចម្ការសមុច្ច័យដំណាំគ្របដីចំនួន១៧ប្រភេទ

- ការស្រង់ទិន្នន័យឧតុនិយម និងតំហែទាំឧបករណ៍ Sap Flow និង Flux Tower
- ការប្រមូលយកសំណាកទឹកជ័រតាមបណ្តាចម្ការពិសោធន៍ទាំងនៅក្នុង និងក្រៅស្ថានីយ៍អនុវត្ត ដើម្បីធ្វើការវិភាគសរីរសាស្ត្រទឹកជ័រ (LD) បានចំនួន៩៨៦សំណាក
- វិភាគស្តង់ដាសរីរសាស្ត្រទឹកជ័រ ចំនួន២៦លើក ដើម្បីផ្ទៀងផ្ទាត់វត្ថុធាតុគីមី។

៤១- ផ្នែកមន្ទីរពិសោធន៍យថាប្រភេទ

- ការធ្វើតេស្តយថាប្រភេទកៅស៊ូចំនួន៣៧០ភាគសំណាក សម្រាប់វាយតម្លៃគុណភាពកែច្នៃរបស់រោង-ចក្រ CSR និងពិនិត្យគុណភាពកៅស៊ូប្រភេទ RSS និងគុណភាពកៅស៊ូប្រភេទ CSR CV សម្រាប់និស្សិតកម្មសិក្សា និងការស្រាវជ្រាវ
- ការរៀបចំរបាយការណ៍សរុបអំពីលទ្ធផលធ្វើតេស្តប្រៀបធៀបមន្ទីរពិសោធន៍ក្នុងស្រុក (Laboratories Parallel Test) ចំនួន៤លើក គឺលើកទី ៤៤, ៤៥, ៤៦ និងទី ៤៧ ដើម្បីវាយតម្លៃសមត្ថភាពមន្ទីរពិសោធន៍មូលដ្ឋាន ភ្ជាប់ប្រកាសលេខ៤០៤ប្រក.កសក ចុះថ្ងៃទី០១ ខែកញ្ញា ឆ្នាំ២០០៨ របស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- ការធ្វើតេស្តអន្តរមន្ទីរពិសោធន៍ជាមួយ IRA ចំនួន២លើក (លើកទី១១៤ និង១១៥) ដើម្បីទទួលស្គាល់ជាមន្ទីរពិសោធន៍យោងនៅក្នុងតំបន់ចំពោះប្រភេទកៅស៊ូ TSRs
- ការត្រួតពិនិត្យតាមដាន និងវាយតម្លៃមន្ទីរពិសោធន៍មូលដ្ឋាន និងរោងចក្រកែច្នៃកៅស៊ូ CSR នៃក្រុមហ៊ុនស៊ីហ្សវីសសស៍ (ខេមបូឌា) លីមីតធីត ចំការកៅស៊ូស្នួល ចំនួន២លើក
- ការត្រួតពិនិត្យតាមដាន និងវាយតម្លៃ ហើយនិងចុះបញ្ជីការរោងចក្រកែច្នៃកៅស៊ូ CSR និងទទួលស្គាល់មន្ទីរពិសោធន៍មូលដ្ឋាន នៃក្រុមហ៊ុនស៊ីធីវ៉ាប់ប៊ើរ ខូ., អិលធីឌី
- ការចូលរួមការងារជាមួយជំនាញការ និងក្រុមវាយតម្លៃនៃគម្រោងអង្គការ UNIDO ក្នុងការរកដំណោះស្រាយ និងមូលហេតុលើឧបករណ៍ជំនួយដែលត្រូវធ្វើតេស្ត និងវាយតម្លៃទទួលស្គាល់ពី BoA
- ការចូលរួមប្រជុំជាមួយក្រុមការងារបច្ចេកទេសផលិតផលកៅស៊ូ (RBPWG: Rubber-based Product Working Group) ក្នុងការកំណត់ស្តង់ដា និងសុខដុមរមនីយកម្មរបស់អាស៊ានចំនួន៤៦ស្តង់ដាសម្រាប់មន្ទីរពិសោធន៍ យោងអាស៊ាន (ARLN: ASEAN Rubber Laboratory Network) នៅលើវិសាលភាពនៃ ISO/IEC 17025
- ការទទួលនូវការត្រួតពិនិត្យ និងវាយតម្លៃលើតេស្តបន្ថែម ហើយនិងអនុវត្តបំពេញលក្ខខណ្ឌតម្រូវការវិញ្ញាបនបត្រ ទទួលស្គាល់តាមស្តង់ដាអន្តរជាតិ ISO/IEC 17025:2005 ពីក្រុមត្រួតពិនិត្យ BoA សម្រាប់សមត្ថភាពមន្ទីរពិសោធន៍ ធ្វើតេស្ត និងព្យាសកម្មឧបករណ៍ (General requirements for the competence of testing and calibration laboratories) និងបន្ថែមវិសាលភាពលើតេស្តកៅស៊ូសមាស និងផលិតផលកៅស៊ូ (Compound Rubber and Rubber Products) របស់មន្ទីរពិសោធន៍ជាតិយថាប្រភេទ សម្រាប់ការរក្សាសុពលភាពឆ្នាំ២០១៦
- ការធ្វើបច្ចុប្បន្នភាពលើកម្រងព័ត៌មានសេវាសាធារណៈរបស់ **វសកក** ដើម្បីបញ្ចូលក្នុងប្រព័ន្ធស្មាត-ហ្វូនសម្រាប់ ការផ្សព្វផ្សាយព័ត៌មានផ្លូវការ
- ការរៀបចំអត្ថបទនៃការស្រាវជ្រាវឥទ្ធិពលអ៊ីដ្រុកស៊ីលអាមីនស៊ុលផាតណឺតលើការធ្វើរ៉ុលកានីសាស្យុងកៅស៊ូសន្លឹក (RSS CV)។

៤២- ចូលរួមវគ្គបណ្តុះបណ្តាល និងសិក្ខាសាលា

- ការចូលរួមសិក្ខាសាលាអន្តរជាតិរបស់មន្ត្រីចំនួន០៥រូប ស្តីអំពី "វិធីសាស្ត្រក្នុងការសរសេរអត្ថបទបច្ចេកទេស ដើម្បីបោះពុម្ពផ្សាយ" ដែលប្រព្រឹត្តទៅនៅថ្ងៃទី២០ ខែវិច្ឆិកា ឆ្នាំ២០១៦ នៅខេត្តសៀមរាប
- ការបញ្ជូនមន្ត្រីចំនួន០៣រូបទៅចូលរួមវគ្គបណ្តុះបណ្តាលខ្លីនៅប្រទេសចិនចំនួន០២វគ្គស្តីអំពី (១) វិធានការ ចម្រុះការពារជំណាំ (២) ការផ្ទេរបច្ចេកវិទ្យាពាក់ព័ន្ធនឹងការដាំដុះ ការបំប៉ោ ការប្រើប្រាស់ជី ការបង្កាត់ពូជ និងជំងឺកៅស៊ូ
- ការសរសេរអត្ថបទបច្ចេកទេស និងការធ្វើបទបង្ហាញចំនួន០៥ នៅក្នុងសន្និសីទប្រចាំឆ្នាំនៃក្រុមប្រឹក្សាស្រាវជ្រាវ និងអភិវឌ្ឍកៅស៊ូអន្តរជាតិឆ្នាំ២០១៦។
- ចូលរួមវគ្គបណ្តុះបណ្តាលជាអ្នកវាយតម្លៃទទួលស្គាល់មន្ទីរពិសោធន៍និងព្យាសកម្ម ISO/IEC 17025 ដើម្បីទទួលស្គាល់ជាអ្នកវាយតម្លៃថ្នាក់ជាតិ និងអន្តរជាតិ។
- ការចូលរួមសិក្ខាសាលាអន្តរជាតិរបស់មន្ត្រី ***វសកក*** ចំនួន០៧លើក នៅបណ្តាប្រទេសជាសមាជិកនៃ IRRDB។

ការងារវិទ្យាស្ថានស្រាវជ្រាវកៅស៊ូកម្ពុជាមានលម្អិតក្នុងបទបង្ហាញទី៦។

## ២.៥ ការងារសហប្រតិបត្តិការអន្តរជាតិ

### ២.៥.១ សមាគមបណ្តាប្រទេសផលិតកៅស៊ូធម្មជាតិ (ANRPC)

៤៣- សមាគមបណ្តាប្រទេសផលិតកៅស៊ូធម្មជាតិ (ANRPC: Association of Natural Rubber Producing Countries) គឺជាអង្គការអន្តររដ្ឋាភិបាលដែលបានបង្កើតឡើងកាលពីឆ្នាំ១៩៧០។ សមាជិកភាពរបស់សមាគមត្រូវបានបើកទូលាយចំពោះរដ្ឋាភិបាលនៃបណ្តាប្រទេសផលិតកៅស៊ូធម្មជាតិ។ គិតរហូតមកដល់ឆ្នាំ២០១៦ សមាគមនេះមានប្រទេសជាសមាជិកចំនួន១១ប្រទេស រួមមាន៖កម្ពុជា ចិន ឥណ្ឌា ឥណ្ឌូនេស៊ី ម៉ាឡេស៊ី ប៉ាពូញូហ្គីណេ ភីលីពីន សិង្ហបុរី ស្រីលង្កា ថៃ និង វៀតណាម។ បរិមាណផលិតផលកៅស៊ូធម្មជាតិរបស់ប្រទេសទាំង១១ គឺមាន៨៩%នៃផលិតផលកៅស៊ូធម្មជាតិក្នុងពិភពលោក។ ***<u>ទស្សនៈវិស័យ</u>*** របស់សមាគម គឺធ្វើឱ្យឧស្សាហកម្មកៅស៊ូធម្មជាតិ មានចីរភាពប្រកបដោយលក្ខណៈសេដ្ឋកិច្ច សង្គម និងបរិស្ថាន។ ***<u>បេសកកម្ម</u>*** គឺកែលម្អជាបន្តបន្ទាប់នូវផលិតភាពនៃកៅស៊ូគ្រួសារ កាត់បន្ថយចំណាយ បង្កើនតម្លៃបន្ថែម ផ្នែកលំហូរខាងក្រោម រកប្រភពប្រាក់ចំណូលបន្ថែម ប្រើប្រាស់លទ្ធភាព និងបទពិសោធន៍កៅស៊ូធម្មជាតិ សម្រាប់ជួយបរិស្ថាន និងបង្កើនសុខុមាលភាពរបស់កសិករកៅស៊ូគ្រួសារ។

៤៤- គោលបំណងរបស់សមាគមបណ្តាប្រទេសផលិតកៅស៊ូធម្មជាតិ ត្រូវបានអនុវត្តនិងផ្តល់ផលប្រយោជន៍ទៅវិញទៅមកដល់គ្រប់ប្រទេសជាសមាជិកគឺ៖

- នាំមកនូវការសម្របសម្រួលក្នុងផលិតកម្មនិងទីផ្សារកៅស៊ូធម្មជាតិ
- លើកកម្ពស់កិច្ចសហប្រតិបត្តិការបច្ចេកទេសក្នុងចំណោមប្រទេសជាសមាជិក
- នាំមកនូវប្រាក់កម្រៃខ្ពស់និងតម្លៃមានស្ថិរភាពសម្រាប់កៅស៊ូធម្មជាតិ។

៤៥- កម្ពុជាបានចូលជាសមាជិកពេញសិទ្ធិ របស់សមាគមនៃបណ្តាប្រទេសផលិតកៅស៊ូធម្មជាតិ កាលពីថ្ងៃទី០៩ ខែកញ្ញា ឆ្នាំ២០០៩។ ការចូលជាសមាជិករបស់កម្ពុជានៅក្នុងសមាគមនេះ គឺជាការធ្វើសមាហរណ៍កម្មវិស័យកៅស៊ូធម្មជាតិកម្ពុជាទៅក្នុងពិភពលោកដែលមានប្រទេសចំនួន១១ចូលរួមជាសមាជិក និងមានប្រទេស

មួយចំនួនកំពុងសិក្សាលទ្ធភាពដើម្បីចូលរួមក្នុងសមាគមនេះផងដែរ។ សមាជិកភាពនេះបានផ្តល់អត្ថប្រយោជន៍ជាច្រើនដល់ឧស្សាហកម្មកៅស៊ូធម្មជាតិនៅកម្ពុជា ដូចជាការទទួលបាននូវព័ត៌មានស្ថិតិ បទពិសោធន៍ បច្ចេកវិទ្យាវិទ្យាសាស្ត្រថ្មីៗ និន្នាការនៃការផ្គត់ផ្គង់ តម្រូវការ ថ្លៃលក់ និងសិក្សាអំពីការប្រែប្រួលអាកាសធាតុពីបណ្តាប្រទេសជាសមាជិកនិងពីស្ថាប័នពាក់ព័ន្ធនានា ជាពិសេស គឺទទួលបានការបណ្តុះបណ្តាលពី Demand-Supply Modeling ក្នុងការរៀបចំស្ថិតិស្តីពីនិន្នាការផ្គត់ផ្គង់និងតម្រូវការកៅស៊ូធម្មជាតិ ក្នុងរយៈពេលជាក់លាក់ណាមួយនាពេលអនាគត និងការបណ្តុះបណ្តាលផ្សេងៗទៀតដែលជាការបណ្តុះបណ្តាលធនធានមនុស្សក្នុងវិស័យកៅស៊ូ។

៤៦- សកម្មភាពរបស់អគ្គនាយកដ្ឋានកៅស៊ូនៅក្នុងសមាគម ឆ្នាំ២០១៦កន្លងមក គឺ៖ (១) ចូលរួមប្រជុំក្រុមជំនាញផ្នែកស្ថិរភាពនីយកម្មតម្លៃកៅស៊ូធម្មជាតិ និងកិច្ចប្រជុំក្រុមជំនាញសម្រាប់ការវិភាគពីការផ្គត់ផ្គង់ និងតម្រូវការកៅស៊ូធម្មជាតិប្រទេសថៃ រយៈពេល៣ថ្ងៃចាប់ពីថ្ងៃទី១៥ ខែមីនា ដល់ថ្ងៃទី១៧ ខែមីនា ឆ្នាំ២០១៦ (២) កិច្ច-ប្រជុំលើកទី៣ របស់ក្រុមជំនាញផ្នែកស្ថិរភាវូបនីយកម្មតម្លៃកៅស៊ូធម្មជាតិ នៃសមាគមបណ្តាប្រទេសផលិតកៅស៊ូធម្មជាតិ (ANRPC) រយៈពេល៣ថ្ងៃ ចាប់ពីថ្ងៃទី១៨ ខែសីហា ដល់ថ្ងៃទី២០ ខែសីហា ឆ្នាំ២០១៦ នៅប្រទេសស្រីលង្កា និង (៣) ឆ្នាំ២០១៦នេះ ព្រះរាជាណាចក្រកម្ពុជា ដែលមានក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ (អគ្គនាយកដ្ឋានកៅស៊ូ) ជាសេនាធិការ បានចូលរួមក្នុងកិច្ចប្រជុំនិងសន្និបាតប្រចាំឆ្នាំ២០១៦ របស់ ANRPC ដែលបានប្រព្រឹត្តទៅអស់រយៈពេល៦ថ្ងៃ គឺចាប់ពីថ្ងៃទី១៧ ដល់ថ្ងៃទី២២ ខែតុលា ឆ្នាំ២០១៦ នៅទីក្រុង Guwahati ប្រទេសឥណ្ឌា តាមកម្មវិធីដែលបានកំណត់ (តារាងទី៤)។ សន្និសីទ កិច្ចប្រជុំ និង សន្និបាតឆ្នាំ២០១៦ របស់ ANRPC មានប្រទេសជាសមាជិកចំនួន១១ប្រទេស ដែលមានអ្នកចូលរួមជាង៣០០នាក់បានប្រព្រឹត្តិទៅប្រកបដោយភាពរលូនល្អនិងជោគជ័យ អាស្រ័យដោយមានការគាំទ្រយ៉ាងពេញទំហឹងពីសំណាក់រាជរដ្ឋាភិបាលនៃប្រទេសឥណ្ឌា ជាម្ចាស់ផ្ទះ និងដោយមានការចូលរួមគាំទ្រយ៉ាងសកម្មពីបណ្តាប្រទេសជាសមាជិក និងពីប្រតិបត្តិករកៅស៊ូនានា រួមមាន៖ អ្នកដាំដុះ អ្នកកែច្នៃ ពាណិជ្ជករ សេដ្ឋវិទូ កម្មន្ត-សាលករ វិស័យឯកជន និងបណ្តាញសារព័ត៌មាន។

តារាងទី៤ កម្មវិធីសន្និសីទ កិច្ចប្រជុំ និង សន្និបាតប្រចាំឆ្នាំ២០១៦ របស់ ANRPC

| **កាលបរិច្ឆេទ** | **កិច្ចប្រជុំ** |
|---|---|
| ១.១២.២ ផ្តល់ព័ត៌មានអំពីការផ្គត់ផ្គង់តម្រូវការ និងតម្លៃកៅស៊ូដល់ប្រតិបត្តិករកៅស៊ូ | ៦២.១ | ៩៩,៨ | ច្បាប់ | ២.១៦០ | ២.១៦០ | ២.១៦០ | ១០០ |
| សរុប | ១២៤.១ | ៩៧,០៣ | | | | | |

9

## ២. លទ្ធផលការងារឆ្នាំ២០១៦(ត)

### ២.៤ ការងារសហប្រតិបត្តិការអន្តរជាតិ

១- ផែនការអភិវឌ្ឍន៍ឧស្សាហកម្មកៅស៊ូ នៅតំបន់ត្រីកោណអភិវឌ្ឍន៍ កម្ពុជា-ឡាវ-វៀតណាមCLV DTA

- ចូលរួមកិច្ចប្រជុំថ្នាក់ឧត្តមមន្ត្រីលើកទី១១ ស្តីពីតំបន់ត្រីកោណអភិវឌ្ឍន៍ នៃប្រទេសកម្ពុជា ឡាវ វៀតណាម (CLV DTA)ចាប់ពីថ្ងៃទី៣១ ខែតុលា ឆ្នាំ២០១៦ដល់ថ្ងៃទី០១ ខែវិច្ឆិកា ឆ្នាំ២០១៦ នៅខេត្តដាក់ណុងប្រទេសវៀតណាម។
- ចូលរួមកិច្ចប្រជុំកំពូលថ្នាក់នាយករដ្ឋមន្ត្រីលើកទី៩ នៃប្រទេសទាំង៣ នាថ្ងៃទី២៣ ខែវិច្ឆិកា ឆ្នាំ២០១៦ នៅខេត្តសៀមរាប ដើម្បីជាកំណត់ត្រា។

10

## ២. លទ្ធផលការងារឆ្នាំ២០១៦(ត)

- សេចក្តីប្រកាសរួម នៃកិច្ចប្រជុំកំពូលថ្នាក់នាយករដ្ឋមន្ត្រីលើក ទី៩ នៃប្រទេសទាំង៣ នៅខេត្តសៀមរាប បានជម្រុញអោយក្រសួងកសិកម្ម នៃប្រទេសទាំង៣ព្រាងផែនការអភិវឌ្ឍន៍ឧស្សាហកម្មកៅស៊ូ សម្រាប់តំបន់ត្រីកោណអភិវឌ្ឍន៍ ដើម្បីដាក់ជូនកិច្ចប្រជុំកំពូលថ្នាក់នាយករដ្ឋមន្ត្រីលើកទី១០និងបានកំណត់ ប្រទេសម្ចាស់ផ្ទះនៃប្រទេសទាំង៣ គឺរៀបចំធ្វើនៅប្រទេសវៀតណាម នៅឆ្នាំ២០១៨។

11

## ២. លទ្ធផលការងារឆ្នាំ២០១៦(ត)

២-អនុស្សរណៈនៃការយោគយល់(MoU)ស្តីពីកិច្ចសហប្រតិបត្តិការក្នុងវិស័យកៅស៊ូធម្មជាតិជាមួយភាគីចិន:

- បានលើកសំណើគម្រោងចំនួន៣ផ្នែកៈ (១)គម្រោងបណ្តុះបណ្តាល និងអភិវឌ្ឍន៍ធនធានមនុស្សក្នុងវិស័យកៅស៊ូ(២)គម្រោងទស្សនកិច្ចសិក្សាផ្លាស់ប្តូរបទពិសោធន៍និង (៣)គម្រោងជំនួយឧបត្ថម្ភគាំទ្រ ហិរញ្ញប្បទាន បានបញ្ជូនទៅក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ។

12

## ២. លទ្ធផលការងារឆ្នាំ២០១៦ (ត)

- បានចូលរួមវគ្គសិក្ខាសាលា ស្តីពីផលិតកម្មនិងការកែច្នៃជ័រកៅស៊ូធម្មជាតិ សម្រាប់អ្នកអាជីពកៅស៊ូកម្ពុជា និងមីយ៉ាន់ម៉ា (Natural Rubber Producing and Processing Seminar of Cambodia and Myanmar's Rubber Jobholder) ដោយមានការឧបត្ថម្ភគាំទ្រពីមន្ទីរកសិកម្មខេត្តហៃណាន និងបណ្ឌិតសភាវិទ្យាសាស្ត្រកសិកម្មតំបន់ត្រូពិកចិន និងរៀបចំឡើងដោយមជ្ឈមណ្ឌលសហប្រតិបត្តិការខេត្តហៃណានសហការជាមួយវិទ្យាស្ថានវិទ្យាសាស្ត្រ និងពត៌មានបច្ចេក វិទ្យាកសិកម្មចិនដែលបានប្រព្រឹត្តិទៅចាប់ពីថ្ងៃទី១៨-២៣ ខែវិច្ឆិកា ឆ្នាំ២០១៦ មានសិក្ខាកាមពីអគ្គនាយកដ្ឋានកៅស៊ូ០៦រូប បានចូលរួម។

13

## ២. លទ្ធផលការងារឆ្នាំ២០១៦ (ត)




14

## ២. លទ្ធផលការងារឆ្នាំ២០១៦ (ត)




15

## ២. លទ្ធផលការងារឆ្នាំ២០១៦ (ត)




16

## ៣. បញ្ហាប្រឈមនិងដំណោះស្រាយ (ត)

### ៣.៣ តារាងម៉ាទ្រីត

| បញ្ហាប្រឈម | ដំណោះស្រាយ | អង្គភាពទទួលខុសត្រូវ |
|---|---|---|
| -ការផ្តល់របាយការណ៍របស់ចម្ការកៅស៊ូ កសិឧស្សាហកម្ម និងសម្បទានដីសេដ្ឋកិច្ចមួយចំនួនមិនបានទាន់ពេលវេលា | -ជំរុញការផ្តល់របាយការណ៍របស់ចម្ការកៅស៊ូ កសិឧស្សាហកម្ម និងសម្បទានដីសេដ្ឋកិច្ចបានទាន់ពេលវេលា | អក និង កសក |
| -តម្លៃជ័រកៅស៊ូធ្លាក់ចុះ | -យន្តការ និងវិធានការនានា | អក.កសក.សហវ អាជ្ញាធរដែនដី |
| -ការទទួលព័ត៌មាន និងចំណេះដឹងរបស់កសិករកៅស៊ូគ្រួសារអំពីទីផ្សារកៅស៊ូនៅមានកម្រិត | -ជំរុញបណ្តុះបណ្តាលនិងផ្សព្វផ្សាយអំពីទីផ្សារកៅស៊ូ ដល់កសិករកៅស៊ូគ្រួសារ | អក |
| -ធនធានមនុស្សនិងសម្ភារបម្រើការងារ។ | -ពង្រឹង ផ្តល់ធនធានមនុស្ស និងសម្ភារបម្រើការងារបន្ថែមទៀត | អក កសក សហវ |

17

## ៤. សំណូមពរ

នាយកដ្ឋានទីផ្សារ និងសហប្រតិបត្តិការអន្តរជាតិ ស្នើសុំអង្គភាព ឬស្ថាប័នពាក់ព័ន្ធជួយជម្រុញ និងដោះស្រាយនូវរាល់បញ្ហាប្រឈមដែលបានជម្រាបជូនខាងលើដើម្បីអនុវត្តការងារបន្តឲ្យទទួលបានជោគជ័យ។

18

## ៥. សន្និដ្ឋាន

ការអនុវត្តការងារក្នុងឆ្នាំ២០១៦កន្លងទៅ ថ្នាក់ដឹកនាំ និងមន្ត្រីនៃនាយកដ្ឋានទីផ្សារ និងសហប្រតិបត្តិការអន្តរជាតិ បានខិតខំជំនះរាល់បញ្ហាប្រឈម និងការលំបាកនានារហូតសម្រេចបានជោគជ័យតាមផែនការគ្រោងទុក ក្រោមការណែនាំ និងតម្រង់ទិសពីថ្នាក់ដឹកនាំអគ្គនាយកដ្ឋានកៅស៊ូ និងក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ។

19

## ៦. ទិសដៅការងារឆ្នាំ២០១៧

- បន្តអនុវត្តចង្កោមសកម្មភាព នៃអនុកម្មវិធី១.១២
- បន្តខិតខំផ្សព្វផ្សាយនិងបណ្តុះបណ្តាលអំពីទីផ្សារកៅស៊ូដល់កសិករ និងប្រតិបត្តិករកៅស៊ូ
- ខិតខំទំនាក់ទំនងជាមួយដៃគូអភិវឌ្ឍន៍ ទីភ្នាក់ងារកៅស៊ូ និងអង្គការកៅស៊ូអន្តរជាតិនានា លើកិច្ចសហប្រតិបត្តិការក្នុងក្របខ័ណ្ឌការងារស្រាវជ្រាវ និងអភិវឌ្ឍន៍បច្ចេកវិជ្ជា វិទ្យាសាស្ត្រ
- បន្តសិក្សាស្រាវជ្រាវព័ត៌មានអំពីការផ្គត់ផ្គង់ តម្រូវការ ការប្រើប្រាស់កៅស៊ូ និងនិន្នាការតម្លៃកៅស៊ូលើទីផ្សារក្នុង និងក្រៅប្រទេស

20

## ៦. ទិសដៅការងារឆ្នាំ២០១៧(ត)

- បន្តការងារផែនការអភិវឌ្ឍន៍ឧស្សាហកម្មកៅស៊ូ នៅតំបន់ត្រីកោណអភិវឌ្ឍន៍ នៃប្រទេសទាំងបីកម្ពុជា ឡាវ វៀតណាម(CLV DTA)
- បន្តតាមដានលើវឌ្ឍនភាព នៃកិច្ចសហប្រតិបត្តិការ ជាមួយភាគីចិន និងបណ្តាប្រទេសជាដៃគូរ
- បន្តជុំរុញការរៀបចំផែនការសកម្មភាពការងារ សំណើគម្រោង និងទស្សនាទាន នៃគម្រោងពាក់ព័ន្ធនឹង វិស័យឧស្សាហកម្មកៅស៊ូធម្មជាតិ
- បន្តអនុវត្តការរៀបចំចងក្រងខ្សែចង្វាក់តម្លៃកៅស៊ូធម្មជាតិនៅកម្ពុជាឱ្យបានចប់តាមការគ្រោងទុក
- អនុវត្តភារកិច្ចចរន្តនិងភារកិច្ចផ្សេងៗទៀតដែលថ្នាក់ដឹកនាំប្រគល់ឲ្យ។

21

## វគ្គបណ្តុះបណ្តាលនិងផ្សព្វផ្សាយស្តីពីវិធានការបង្កើនថ្លៃជ័រកៅស៊ូធម្មជាតិក្នុងស្រុក នៅខេត្តត្បូងឃ្មុំ



22

## វគ្គបណ្តុះបណ្តាលនិងផ្សព្វផ្សាយស្តីពីវិធានការបង្កើនថ្លៃកៅស៊ូធម្មជាតិក្នុងស្រុក នៅខេត្តក្រចេះ



23







សូមអរគុណ

24

# បទបង្ហាញទី៣ លទ្ធផលការងារឆ្នាំ២០១៦ និងលើកទិសដៅការងារឆ្នាំ២០១៧ របស់នាយកដ្ឋានកែច្នៃផលិតផលកៅស៊ូ
















| ចង្កោមសកម្មភាព | សូចនាករ | គោលដៅ | លទ្ធផល | | ខេត្តគោលដៅ |
|---|---|---|---|---|---|
| | | | សម្រេច | ភាគរយ | |
| ១.១៣.១ *ចុះស្រង់ស្ថិតិរោងចក្រសិប្បកម្ម* | ខេត្តត្រូវបានស្រង់រោងចក្រ សិប្បកម្មកែច្នៃជ័រនិងឈើកៅស៊ូ | ១០ | ១០ | ១០០ | កំពង់ចាម មណ្ឌលគិរី ស្វាយរៀង ព្រៃវែង ព្រះសីហនុ កោះកុង បាត់ដំបង ប៉ៃលិន បន្ទាយមានជ័យ ឧត្តរមានជ័យ |
| ១.១៣.២ *ផ្សព្វផ្សាយបច្ចេកទេសកែច្នៃដល់ប្រតិបត្តិករកៅស៊ូ* | ចំនួនប្រតិបត្តិករកៅស៊ូ ទទួលបានចំណេះដឹងពីបច្ចេកទេសកែច្នៃជ័រកៅស៊ូនិងភាកសំណល់រាវ | ១២០ | ១២០ | ១០០ | កំពង់ចាម ក្រចេះ |




| ចង្កោមសកម្មភាព | សូចនាករ | គោលដៅ | លទ្ធផល | | ខេត្តគោលដៅ |
|---|---|---|---|---|---|
| | | | សម្រេច | ភាគរយ | |
| ១.១៣.៣ *ផ្សព្វផ្សាយនិងបណ្តុះបណ្តាលបច្ចេកទេសកែច្នៃជ័រកៅស៊ូសន្លឹកដល់សហគមន៍កៅស៊ូគ្រួសារ* | កសិករកៅស៊ូគ្រួសារក្នុងសហគមន៍កៅស៊ូគ្រួសារត្រូវបានបណ្តុះបណ្តាល | ២៥០ | ២៥០ | ១០០ | កំពង់ចាម ត្បូងឃ្មុំ ស្ទឹងត្រែង ក្រចេះ |

## ២. លទ្ធផល (ត)

នាយកដ្ឋានកែច្នៃផលិតផលកៅស៊ូ

### ២.១ ការចុះស្រង់ស្ថិតិរោងចក្រ សិប្បកម្ម

| ល.រ | រោងចក្រ សិប្បកម្ម | ២០១៣ | ២០១៤ | ២០១៥ | ២០១៦ | សរុប |
|---|---|---|---|---|---|---|
| ១ | រោងចក្រកែច្នៃជ័រកៅស៊ូដុំTSR | ២៩ | ៥ | ២ | ០១ | ៣៧ |
| ២ | សិប្បកម្មកែច្នៃជ័រកៅស៊ូសន្លឹកRSS | ៣៧ | ២៣ | ២០ | ០៥ | ៨៥ |
| ៣ | រោងចក្រកែច្នៃឈើកៅស៊ូ | ៤ | ០ | ០ | ០ | ៤ |
| | សរុប | ៧០ | ២៨ | ២២ | ០៦ | ១២៦ |

GDR Feb., 2017




## ២. លទ្ធផល (ត)

### ២.២ លទ្ធផលនៃការអនុវត្តចង្កោមសកម្មភាពរបស់អនុកម្មវិធី១.១៣

| ចង្កោម សកម្មភាព | ថវិកា (លាន) (លាន) | | ឯកតា សូចនាករ | ២០១៥ សម្រេចបាន | ២០១៦ | | |
|---|---|---|---|---|---|---|---|
| | ២០១៦ | % | | | គោលដៅ | សម្រេចបាន | % |
| ១.១៣.១ ស្រង់ស្ថិតិរោងចក្រ សិប្បកម្មកែច្នៃផលិតផលកៅស៊ូ | 14,2 | 99.56 | ចំនួនខេត្ត | 22 (រោងចក្រសិប្បកម្ម) | 10 | 10 | 100 |
| ១.១៣.២ ផ្សព្វផ្សាយបច្ចេកទេស កែច្នៃដល់ប្រតិបត្តិករកៅស៊ូ | 25,7 | 96.73 | ចំនួនប្រតិបត្តិករ | 41 | 120 | 120 | 100 |
| ១.១៣.៣ ផ្សព្វផ្សាយនិងបណ្តុះបណ្តាលបច្ចេកទេសកែច្នៃជ័រកៅស៊ូ សន្លឹក USS ដល់សហគមន៍កៅស៊ូ គ្រួសារ | 46,6 | 88.90 | ចំនួនកសិករ | 211 | 250 | 250 | 100 |









## ៣. បញ្ហាប្រឈម និងដំណោះស្រាយ

**តារាងម៉ាទ្រីក**

| បញ្ហាប្រឈម | ដំណោះស្រាយ | អង្គភាពទទួលខុសត្រូវ |
|---|---|---|
| ❑ ការយល់ដឹងពីបច្ចេកទេសកែច្នៃផលិតផលកៅស៊ូរបស់មន្ត្រី នៅមានកម្រិត | ✓ ស្នើសុំបណ្តុះបណ្តាលមន្ត្រីរយៈពេលវែង ឬខ្លី<br>▪ ជំនាញបច្ចេកទេសថ្មីៗផ្នែកកែច្នៃផលិតផលកៅស៊ូទាំងក្នុងនិងក្រៅប្រទេស<br>▪ ជំនាញបច្ចេកទេសកុំព្យូទ័រ<br>▪ ភាសាអង់គ្លេស<br>✓ បន្តលើកទឹកចិត្តឬជំរុញឱ្យមានការសិក្សានិងស្រាវជ្រាវ ដោយខ្លួនឯង | ☞ អគ្គនាយកដ្ឋានកៅស៊ូ<br>☞ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ<br>☞ ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ |

13

## ៣. បញ្ហាប្រឈម និងដំណោះស្រាយ (ត)

**តារាងម៉ាទ្រីក (ត)**

| បញ្ហាប្រឈម | ដំណោះស្រាយ | អង្គភាពទទួលខុសត្រូវ |
|---|---|---|
| ❑ ចំណេះដឹងទូទៅ និងការយល់ដឹងពីបច្ចេកទេសកែច្នៃរបស់ម្ចាស់កៅស៊ូគ្រួសារ និងម្ចាស់រោងចក្រ សិប្បកម្មមួយចំនួននៅមានកម្រិត | ✓ កែសម្រួលឯកសារបច្ចេកទេសឱ្យមានលក្ខណៈងាយស្រួលយល់<br>✓ បង្ហាញនិងអនុវត្តលំហាត់ជំនួយស្មារតីឱ្យបានច្រើន ព្រមទាំងការអនុវត្តជាក់ស្តែង<br>✓ បង្ហាញជាវីដេអូក្លីប<br>✓ ធ្វើទស្សនៈកិច្ចសិក្សា<br>✓ បង្កើតមណ្ឌលកែច្នៃបង្ហាញសម្រាប់ម្ចាស់កៅស៊ូក្នុងសហគមន៍កៅស៊ូគ្រួសារ<br>✓ ជំរុញឱ្យមានការបង្រៀនផ្នែកចំណេះដឹងទូទៅនៅក្នុងសហគមន៍កៅស៊ូគ្រួសារ | ☞ នាយកដ្ឋានកែច្នៃផលិតផលកៅស៊ូ<br>☞ អគ្គនាយកដ្ឋានកៅស៊ូ<br>☞ អាជ្ញាធរដែនដីនៅតាម មូលដ្ឋាន<br>☞ មន្ទីរឬការិយាល័យអប់រំនៃក្រសួងអប់រំ យុវជន និងកីឡា |

14

## ៣. បញ្ហាប្រឈម និងដំណោះស្រាយ (ត)

**តារាងម៉ាទ្រីក (ត)**

| បញ្ហាប្រឈម | ដំណោះស្រាយ | អង្គភាពទទួលខុសត្រូវ |
|---|---|---|
| ❑ ម្ចាស់ ឬតំណាងរោងចក្រ សិប្បកម្មកែច្នៃផលិតផលកៅស៊ូមួយចំនួនមិនបានសហការ និងមិនផ្តល់ព័ត៌មានទាក់ទងនឹងផលិតផលដែល បានអនុវត្តជាក់ស្តែង | ✓ ពន្យល់ពីសារៈសំខាន់នៃសម្រង់ព័ត៌មាន<br>✓ ពង្រឹងការអនុវត្តលិខិតបទដ្ឋានគតិយុត្តិដែលមានស្រាប់<br>✓ ជំរុញម្ចាស់រោងចក្រ សិប្បកម្មឱ្យគោរពតាមការណែនាំរបស់អគ្គនាយកដ្ឋានកៅស៊ូ<br>✓ ជំរុញបញ្ចប់ការបង្កើតច្បាប់កៅស៊ូ | ☞ ន.ក.ផ.ក.<br>☞ អគ្គនាយកដ្ឋានកៅស៊ូ<br>☞ អ.ក. និងក.ស.ក.<br>☞ ក.ស.ក. ទីស្តីការគណៈរដ្ឋ មន្ត្រីនិងរដ្ឋសភាជាតិ |
| ❑ ការធ្លាក់ថ្លៃកៅស៊ូ | ✓ បញ្ជាក់មូលហេតុនៃការធ្លាក់ថ្លៃ និងយន្តការសម្រាប់ដោះស្រាយ | ☞ នាយកដ្ឋានកែច្នៃផលិតផលកៅស៊ូ<br>☞ អគ្គនាយកដ្ឋានកៅស៊ូ |

15

## ៤. សន្និដ្ឋាន

នាយកដ្ឋានកែច្នៃផលិតផលកៅស៊ូ

➤ ក្នុងឆ្នាំ២០១៦នេះ ទោះបីជាមានបញ្ហាប្រឈមខ្លះៗ នៅក្នុងការបំពេញការងារក៏ដោយ ក៏ការអនុវត្តការងារកន្លងមកសម្រេចបាននូវលទ្ធផលជាផ្លែផ្កា ដោយសារការខិតខំប្រឹងប្រែង និងការយកចិត្តទុកដាក់របស់ថ្នាក់ដឹកនាំ និងមន្ត្រីទាំងអស់ ព្រមទាំងការចូលរួមពីស្ថាប័នពាក់ព័ន្ធ ពិសេសការណែនាំតម្រង់ទិសរបស់ឯកឧត្តមប្រតិភូរាជរដ្ឋាភិបាលកម្ពុជា ទទួលបន្ទុកជា អគ្គនាយក នៃអគ្គនាយកដ្ឋានកៅស៊ូ។

GDR
Feb., 2017

16

## ៥. សំណូមពរ

នាយកដ្ឋានកែច្នៃផលិតផលកៅស៊ូ

➤ ដើម្បីឆ្លើយតបទៅនឹងបញ្ហាប្រឈមនិងការលំបាកខាងលើ នាយកដ្ឋានកែច្នៃផលិតផលកៅស៊ូស្នើសុំអង្គភាពនិងស្ថាប័នពាក់ព័ន្ធដែលទទួលខុសត្រូវ ធ្វើយ៉ាងណាជួយជំរុញនិងដោះស្រាយឱ្យបានទាន់ពេលវេលា ដើម្បីទុកលទ្ធភាពឱ្យនាយកដ្ឋានកែច្នៃផលិតផលកៅស៊ូ ងាយស្រួលក្នុងការអនុវត្តការងារបន្តនាឆ្នាំ២០១៧នេះ ក៏ដូចជានៅឆ្នាំក្រោយៗទៀត

➤ ស្នើសុំសម្ភារការិយាល័យ ដែលទាក់ទងនឹងដំណើរការការងាររបស់នាយកដ្ឋាន

➤ ស្នើសុំមន្ត្រីផ្នែកវិស្វកម្មកសិកម្ម ព័ត៌មានវិទ្យា និងវិទ្យាសាស្ត្រគីមី។

GDR
Feb., 2017

17

## ៦. ទិសដៅ

នាយកដ្ឋានកែច្នៃផលិតផលកៅស៊ូ

**៦.១ ការងារតាមកម្មវិធី**

| ឈ្មោះសូចនាករ | សូចនាករ | គោលដៅ | | | ខេត្តគោលដៅ |
|---|---|---|---|---|---|
| | | ២០១៦ | ២០១៧ | % | |
| **១.១៣.១** *ផ្សព្វផ្សាយបច្ចេកទេសកែច្នៃដល់ប្រតិបត្តិករកៅស៊ូ* | ចំនួនប្រតិបត្តិករកៅស៊ូ | ១២០ | ១២០ | 0 | •កំពង់ចាម<br>•ត្បូងឃ្មុំ |

GDR
Feb., 2017

18




| ឈ្មោះសូចនាករ | សូចនាករ | គោលដៅ | | | មូលហេតុ | ខេត្តគោលដៅ |
|---|---|---|---|---|---|---|
| | | ២០១៦ | ២០១៧ | % | | |
| ១.១៣.២ *ផ្សព្វផ្សាយនិងបណ្តុះបណ្តាលបច្ចេកទេសកែច្នៃជ័រកៅស៊ូសន្លឹកដល់សហគមន៍កៅស៊ូគ្រួសារ* | កសិករក្នុងសហគមន៍កៅស៊ូគ្រួសារត្រូវបានបណ្តុះបណ្តាល | ២៥០ | ៣០០ | ២០ | • បញ្ជ្រៀបព័ត៌មានស្តីពីការកែច្នៃជ័រកៅស៊ូសន្លឹកUSS និងការបង្កើតមណ្ឌលកែច្នៃរួមដល់សហគមន៍កៅស៊ូគ្រួសារ<br>• ចំនួនផ្ទៃដីចៀរជ័ររបស់កសិករកៅស៊ូគ្រួសារ ដែលជាក្រុមគោលដៅមានការកើនឡើង | • បាត់ដំបង<br>• មណ្ឌលគិរី<br>• កំពង់ធំ<br>• ព្រះវិហារ<br>• រតនគិរី<br>• ស្ទឹងត្រែង |






# បទបង្ហាញទី៤ លទ្ធផលការងារឆ្នាំ២០១៦ និងលើកទិសដៅការងារឆ្នាំ២០១៧ របស់នាយកដ្ឋានរដ្ឋបាល និងនីតិកម្ម

## លទ្ធផលការងារ

របស់នាយកដ្ឋានរដ្ឋបាល និងនីតិកម្ម
ឆ្នាំ២០១៦ និងទិសដៅការងារឆ្នាំ២០១៧

លូង សុខខេង
អនុប្រធាននាយកដ្ឋានរដ្ឋបាល និងនីតិកម្ម

អគ្គនាយកដ្ឋានកៅស៊ូ, ថ្ងៃទី២៧-២៨ ខែកុម្ភៈ ឆ្នាំ២០១៧ 1

## មាតិកា

- ១ • សេចក្តីផ្តើម
- ២ • លទ្ធផល
- ៣ • បញ្ហាប្រឈម និងដំណោះស្រាយ
- ៤ • សន្និដ្ឋាន
- ៥ • សំណូមពរ
- ៦ • ទិសដៅ

## ១-សេចក្តីផ្តើម

ក្នុងនាមជាសេនាធិការរបស់អគ្គនាយកដ្ឋានកៅស៊ូ នាយកដ្ឋានរដ្ឋបាល និងនីតិកម្មបានអនុវត្តភារកិច្ចរបស់ខ្លួនយ៉ាងសកម្មដូចមានចែងក្នុងអនុក្រឹត្យ១៨៨អនក្រ.បក ចុះថ្ងៃទី១៤ ខែវិច្ឆិកា ឆ្នាំ២០០៨ និងអនុវត្តភារកិច្ចផ្សេងៗទៀតដែលថ្នាក់ដឹកនាំប្រគល់ឲ្យ សំដៅរួមចំណែកអភិវឌ្ឍន៍ឧស្សាហកម្មកៅស៊ូធម្មជាតិនៅកម្ពុជាឲ្យកាន់តែមានភាពរីកចម្រើនឡើងបន្ថែមទៀត។

## ១.១-រចនាសម្ព័ន្ធអគ្គនាយកដ្ឋានកៅស៊ូ




3

## ១.២-ធនធានមនុស្ស




មន្ត្រីរាជការ នៃអគ្គនាយកដ្ឋានកៅស៊ូសរុប១៩៤នាក់ (ស្រី៥៤នាក់)។ 4

## ១.៣-កម្រិតជំនាញមន្ត្រីរាជការតាមនាយកដ្ឋាន

| កម្រិតជំនាញ | ថ្នាក់ដឹកនាំ | រន | នអក | ផហស | កផក | ទសអ | វសកក | សរុប |
|---|---|---|---|---|---|---|---|---|
| បណ្ឌិត | ១ | - | ១ | - | - | - | ១ | ៣ |
| អនុបណ្ឌិត | ៣ | ៤ | - | ៤ | ១ | ២ | ១០ | ២៤ |
| បរិញ្ញាបត្រ | - | ១៣ | ២៣ | ១១ | ១១ | ១០ | ២៩ | ៩៧ |
| មធ្យម | ១ | ៨ | ១ | ៣ | ២ | ៤ | ៦ | ២៥ |
| គ្មាន | - | ១៧ | ៤ | ៦ | ៤ | ៧ | ៧ | ៤៥ |
| សរុប | ៥ | ៤២ | ២៩ | ២៤ | ១៨ | ២៣ | ៥៣ | ១៩៤ |

5

## ១.៤-រចនាសម្ព័ន្ធនាយកដ្ឋានរដ្ឋបាល និងនីតិកម្ម




6

## ១.៥-ភារកិច្ចនាយកដ្ឋានរដ្ឋបាល និងនីតិកម្ម

1. រៀបចំគ្រប់គ្រង បែងចែក និងទទួលឯកសារចេញចូល លិខិតឧទ្ទេសនាម លិខិតបញ្ជាបេសកកម្ម។
2. បូកសរុប និងធ្វើរបាយការណ៍អំពីសកម្មភាពទូទៅរបស់ អ.ក.។
3. គ្រប់គ្រង និងរៀបចំស្ថិតិមន្ត្រីរាជការ បណ្តុះបណ្តាលធនធានមនុស្ស។
4. រៀបចំបង្កើត រំសាយ ឬកែសម្រួលរចនាសម្ព័ន្ធក្រោមឱវាទ អ.ក.។
5. គ្រប់គ្រងចលនៈ និងអចលនៈទ្រព្យ សន្និធិ និងបញ្ជីសារពើភ័ណ្ឌ។
6. រៀបចំតាក់តែងច្បាប់ និងលិខិតបទដ្ឋាននានាស្តីពីការគ្រប់គ្រងវិស័យកៅស៊ូ។
7. ទទួលបណ្តឹងតវ៉ា ឬវិវាទ និងចុះពិនិត្យ ស្រាវជ្រាវបណ្តឹងតវ៉ានៅតាមចម្ការកៅស៊ូនានា។
8. អនុវត្តភារកិច្ចផ្សេងៗដែលថ្នាក់ដឹកនាំប្រគល់ឱ្យ។

7

## ២-លទ្ធផល

### ២.១-ការងារចរន្ត

1. បានរៀបចំគ្រប់គ្រង បែងចែក និងទទួលឯកសារចេញចូល លិខិតឧទ្ទេសនាម លិខិតបញ្ជាបេសកកម្ម ទាន់ពេលវេលា និងចំគោលដៅ។
2. បានរៀបចំបូកសរុប និងធ្វើរបាយការណ៍អំពីសកម្មភាពទូទៅរបស់ អ.ក.។
3. បានរៀបចំ និងគ្រប់គ្រងស្ថិតិមន្ត្រីរាជការ បណ្តុះបណ្តាលធនធានមនុស្ស ក្នុងក្របខណ្ឌ អ.ក.។
4. បានរៀបចំសំណើសុំតែងតាំង ផ្ទេរសម្រួលភារកិច្ចជូនមន្ត្រីរាជការ តាមសេចក្តីសម្រេចរបស់ថ្នាក់ដឹកនាំ។
5. គ្រប់គ្រងចលនៈ និងអចលនៈទ្រព្យ សន្និធិ និងបញ្ជីសារពើភ័ណ្ឌរបស់ អ.ក.។
6. បានពិនិត្យកែសម្រួលឡើងវិញសេចក្តីព្រាងច្បាប់ស្តីពីកៅស៊ូ និងបានរៀបចំតាក់តែងសេចក្តីព្រាងប្រកាសមួយចំនួន។
7. បានទទួលបណ្តឹងតវ៉ា និងបានចុះពិនិត្យ ស្រាវជ្រាវបណ្តឹងទាំងនោះនៅតាមចម្ការកៅស៊ូផ្ទាល់។
8. អនុវត្តភារកិច្ចផ្សេងៗដែលថ្នាក់ដឹកនាំប្រគល់ឱ្យ។

### ២.២-ការងារអនុវត្តថវិកាកម្មវិធី

ការអនុវត្តអនុកម្មវិធីទី១.១៤៖ លើកកម្ពស់ការគ្រប់គ្រង និងបណ្តុះបណ្តាលធនធានមនុស្ស ក្នុងផ្នែកកៅស៊ូ

| សូចនាករ | ២០១៥ សម្រេចបាន | ២០១៦ | | % |
|---|---|---|---|---|
| | | គោលដៅ | អនុវត្ត | |
| ១- ប្រតិបត្តិករកៅស៊ូទទួលបានការយល់ដឹងពីលិខិតបទដ្ឋានគតិយុត្តអំពីកៅស៊ូ (នាក់)។ | 350 | 400 | 400 | 100 |
| ២- ប្រតិបត្តិករកៅស៊ូទទួលបានការបណ្តុះបណ្តាល និងបង្កើនសមត្ថភាពជំនាញ (នាក់)។ | 30 | 35 | 35 | 100 |

9

ការអនុវត្តចង្កោមសកម្មភាពទី១.១៤.១, ១.១៤.២ និង១.១៤.៣

| ចង្កោមសកម្មភាព | ថវិកា (លាន) | | ឯកតាសូចនាករ | ២០១៥ សម្រេចបាន | ២០១៦ | | % |
|---|---|---|---|---|---|---|---|
| | ២០១៦ | % | | | គោលដៅ | អនុវត្ត | |
| ១- រៀបចំសេចក្តីព្រាងច្បាប់ស្តីពីកៅស៊ូ និងលិខិតបទដ្ឋានគតិយុត្តក្រោមច្បាប់។ | 30.9 | 53,01 | ចំនួនប្រជុំ | 28 | 28 | 28 | 100 |
| ២- ផ្សព្វផ្សាយលិខិតបទដ្ឋានគតិយុត្តនានា ដែលពាក់ព័ន្ធដល់ផ្នែកកៅស៊ូ។ | 57.8 | 98,28 | ចំនួននាក់ | 350 | 400 | 400 | 100 |
| ៣- បណ្តុះបណ្តាលសមត្ថភាពជំនាញដល់ប្រតិបត្តិករកៅស៊ូ។ | 8.7 | 100 | ចំនួននាក់ | 30 | 35 | 35 | 100 |

10

## ៣- បញ្ហាប្រឈម និងដំណោះស្រាយ

| បញ្ហាប្រឈម | ដំណោះស្រាយ | អង្គភាពជួយដោះស្រាយ |
|---|---|---|
| ខ្វះមន្ត្រីជំនាញនីតិកម្ម។ | ជ្រើសរើសមន្ត្រីជំនាញនីតិកម្មបន្ថែម។ | អក. និង កសក. |
| កសិករមកចូលរួមស្តាប់ការផ្សព្វផ្សាយមានការយឺតយ៉ាវមិនទាន់ពេលវេលាកំណត់។ | រំលឹកបន្ថែមដល់កសិករ។ | ក្រុមការងារ អាជ្ញាធរ និងមន្ទីរកសក. |
| សមត្ថភាពមន្ត្រីអនុវត្តគម្រោងនៅមានកម្រិត។ | មន្ត្រីរាជការអនុវត្តគម្រោងបានទទួលការបណ្តុះបណ្តាល។ | អក. កសក. និងសហវ. |
| ធនធានមនុស្សក្នុងនាយកដ្ឋាននៅមានកម្រិត | ជ្រើសរើសមន្ត្រីរាជការបន្ថែម។ | អក. និង កសក. |
| ការទទួលរបាយការណ៍ពីចម្ការកៅស៊ូគ្រប់ប្រភេទមិនបានទាន់ពេលវេលា | ណែនាំ និងមានវិធានការដល់ចម្ការកៅស៊ូគ្រប់ប្រភេទឲ្យផ្តល់របាយការណ៍បានទាន់ពេលវេលាដែលបានកំណត់ | អក. |

## ៤-សន្និដ្ឋាន

ការអនុវត្តការងារក្នុងឆ្នាំ២០១៦កន្លងមកនេះ ទទួលបានលទ្ធផលល្អប្រសើរ អាស្រ័យដោយ៖

- មានការគាំទ្រពីថ្នាក់ដឹកនាំក្រសួង ពិសេសថ្នាក់ដឹកនាំអគ្គនាយកដ្ឋានកៅស៊ូ និងមានការសហការល្អរវាងនាយកដ្ឋាននានា
- មានការសហការពីអាជ្ញាធរដែនដីគ្រប់លំដាប់ថ្នាក់ មន្ទីរកសក.ខេត្ត និងមានការចូលរួមពីគ្រប់ភាគីពាក់ព័ន្ធ
- មានថវិកាសម្រាប់អនុវត្តការងារ
- រួមសហការឈរលើស្មារតីសាមគ្គីគ្នាក្នុងការអនុវត្តការងារបានល្អប្រសើរ
- មន្ត្រីរាជការមានឆន្ទៈចូលរួម។

12

## ៥-សំណូមពរ

១- សូមផ្តល់កុំព្យូទ័រលើតុ និងម៉ាស៊ីនព្រីន ចំនួន០២កុំប្លេ និងកុំព្យូទ័រយួរដៃ ចំនួន០១គ្រឿង។
២- សូមផ្តល់មេដាយ និងប្រកាសនីយបត្រប្រចាំឆ្នាំនីមួយៗ
៣- សូមផ្តល់បន្ថែមមន្ត្រីបច្ចេកទេសជាន់ខ្ពស់។

13

## ៦- ទិសដៅការងារឆ្នាំ២០១៧

### ៦.១-ការងារចរន្ត

បន្តអនុវត្តភារកិច្ចរបស់ខ្លួន ដូចមានចែងក្នុងអនុក្រឹត្យ១៨៨អនក្រ.បក ចុះថ្ងៃទី១៤ ខែវិច្ឆិកា ឆ្នាំ២០០៨ និងភារកិច្ចផ្សេងៗទៀតដែលថ្នាក់ដឹកនាំប្រគល់ឲ្យ ប្រកបដោយស្មារតីទទួលខុសត្រូវខ្ពស់ ធ្វើយ៉ាងណាឲ្យទទួលបានលទ្ធផលល្អប្រសើរ ដើម្បីភាពរីកចម្រើនរបស់អង្គភាព និងដើម្បីវឌ្ឍនភាព នៃឧស្សាហកម្មកៅស៊ូធម្មជាតិនៅកម្ពុជា។

14

### ៦.២-ការងារថវិកាកម្មវិធី

### គោលដៅសូចនាករអនុកម្មវិធីទី១.១៤

| សូចនាករ | 2016 | 2017 | | |
|---|---|---|---|---|
| | | គោលដៅ | គោលដៅកែសម្រួល | មូលហេតុប្រែប្រួល |
| ១- ប្រតិបត្តិករកៅស៊ូទទួលបានការយល់ដឹងពីលិខិតបទដ្ឋានគតិយុត្តអំពីកៅស៊ូ (នាក់)។ | 400 | 400 | | |
| ២- ប្រតិបត្តិករកៅស៊ូទទួលបានការបណ្តុះបណ្តាល និងបង្កើនសមត្ថភាពជំនាញ (នាក់)។ | 35 | 35 | | |

15

### គោលដៅសូចនាករចង្កោមសកម្មភាព

### ការអនុវត្តចង្កោមសកម្មភាពទី១.១៤.១, ១.១៤.២ និង១.១៤.៣

| ចង្កោមសកម្មភាព | សូចនាករ | 2016 | 2017 | |
|---|---|---|---|---|
| | | | គោលដៅ | មូលហេតុប្រែប្រួល |
| ១. ប្រជុំក្រុមការងារ និងថ្នាក់ដឹកនាំ អក. រៀបចំសេចក្តីព្រាងច្បាប់ស្តីពីកៅស៊ូ និងលិខិតបទដ្ឋានក្រោមច្បាប់។ | ចំនួនប្រជុំ | 28 | 28 | |
| ២. ប្រតិបត្តិករកៅស៊ូមានការយល់ដឹងពីលិខិតបទដ្ឋានគតិយុត្តនានាផ្នែកកៅស៊ូមានការកើនឡើង។ | ចំនួននាក់ | 400 | 400 | |
| ៣. សមត្ថភាព ចំណេះដឹងប្រតិបត្តិករកៅស៊ូមានមានការកើនឡើង។ | ចំនួននាក់ | 35 | 35 | |

16

# សូមអរគុណ !




17

# បទបង្ហាញទី៥ លទ្ធផលការងារឆ្នាំ២០១៦ និងលើកទិសដៅការងារឆ្នាំ២០១៧ របស់នាយកដ្ឋានផែនការ ហិរញ្ញវត្ថុ និង ស្ថិតិ


















## ២. លទ្ធផល(ត)

**ការងារផែនការនិងរដ្ឋបាល (ត)**

ការអនុវត្តចង្កោមសកម្មភាព១.១៥.១, ១.១៥.២, ១.១៥.៣, ១.១៥.៤ & ១.១៥.៥

| ចង្កោមសកម្មភាព | ថវិកា (លាន) អនុម័ត ២០១៦ | ថវិកា (លាន) អនុវត្ត % | ឯកតាសូចនាករ | 2015 សម្រេចបាន | 2016 គោលដៅ | 2016 អនុវត្ត | % |
|---|---|---|---|---|---|---|---|
| ១. ពង្រឹងប្រសិទ្ធភាពនៃការអនុវត្តថវិកាកម្មវិធី | 17,8 | (13,7) 76.92% | ចំនួនចុះ | 07 | 08 | 08 | 100,00 |
| ២. បណ្ដុះបណ្ដាលការរៀបចំនិងគ្រប់គ្រងអនុកម្មវិធី | 18,2 | (17,7) 97.16% | ចំនួនប្រជុំ | 11 | 11 | 11 | 100,00 |
| ៣. រៀបចំសន្និបាតឬប្រជុំបូកសរុបប្រចាំឆ្នាំ | 23,1 | (23,1) 99.96% | ចំនួនប្រជុំ | 01 | 01 | 01 | 100,00 |
| ៤. តាមដានការអនុវត្តផែនការកម្មវិធីវិនិយោគកៅស៊ូ និងវាយតម្លៃលទ្ធផលដែលសម្រេចបាន | 72,9 | (68,1) 93.37% | ចំនួនចុះ | 08 | 11 | 11 | 100,00 |
| ៥. គាំទ្រការសម្របសម្រួលការងារកិច្ចការរដ្ឋបាល | 1.928,3 | (2.193,8) 113.77% | | | | | |

## ២. លទ្ធផល(ត)

**ការងារគណនេយ្យ ហិរញ្ញវត្ថុ**

១. បានចូលរួមរៀបចំកសាងគម្រោងផែនការថវិកាឆ្នាំ២០១៧ ទាន់ពេលវេលា។

២.បានសហការជាមួយគណៈប្រតិភូអធិការកិច្ចហិរញ្ញវត្ថុ(ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ) ពិនិត្យការគ្រប់គ្រងចំណូល ចំណាយថវិការដ្ឋ ការគ្រប់គ្រងចំណូលមិនមែនសារពើពន្ធ ការិយបរិច្ឆេទ២០១៥។

៣. បានសុំគោលការណ៍ចំណាយថវិការជូនទេយ្យបុរេប្រទានសម្រាប់អនុវត្ត។

៤. បានសុំគោលការណ៍ធានាចំណាយថវិកាលើការងារលទ្ធកម្មនិងបានធ្វើការប្រគល់ទទួលរួចរាល់។

៥. បានពិនិត្យនិងតាមដានការចំណាយថវិកាកម្មវិធី។

៦. បានចូលរួមប្រជុំនិងសិក្ខាសាលាពាក់ព័ន្ធការងារផែនការ គណនេយ្យ។

៧. អនុវត្តភារកិច្ចចរន្តនិងភារកិច្ចផ្សេងៗដែលថ្នាក់ដឹកនាំប្រគល់ឱ្យ។

8

## ២. លទ្ធផល(ត)

**ការងារគណនេយ្យ ហិរញ្ញវត្ថុ(ត)**

ការប្រៀបធៀបរវាងថវិកាអនុវត្តនិងថវិកាអនុម័ត, 2016 (រៀល)

| ជំពូក | ចំណាត់ថ្នាក់ចំណាយ | អនុម័ត | សម្រេចបាន | % |
|---|---|---|---|---|
| 60 | ការទិញ | 379.700.000 | 362.655.950 | 95,51 |
| 61 | សេវាខាងក្រៅ | 1.408.500.000 | 1.271.634.537 | 90,28 |
| 63 | ពន្ធនិងអាករ | 7.000.000 | 5.750.000 | 82,14 |
| 64 | បន្ទុកបុគ្គលិក | 1.042.800.000 | 1.422.023.680 | 136,37 |
| 65 | ឧបត្ថមធននិងជំនួយសង្គម | 30.000.000 | 29.529.331 | 98,43 |
| | សរុប | 2.868.000.000 | 3.091.593.498 | 107,80 |

9

## ២. លទ្ធផល(ត)

**ការងារគណនេយ្យ ហិរញ្ញវត្ថុ(ត)**

ការប្រៀបធៀបរវាងថវិកាអនុវត្តនិងថវិកាអនុម័តតាមឆ្នាំ




10

## ២. លទ្ធផល(ត)

**ការងារគណនេយ្យ ហិរញ្ញវត្ថុ(ត)**

ការប្រៀបធៀបរវាងថវិកាអនុម័ត២០១៧/២០១៦ តាមជំពូកថវិកា




11

## ២. លទ្ធផល(ត)

**ការងារគណនេយ្យ ហិរញ្ញវត្ថុ(ត)**

ចំណូលរបស់អគ្គនាយកដ្ឋានកៅស៊ូឆ្នាំ២០១៦




12

## ២. លទ្ធផល (ត)

**ការខារស្ថិតិ**

ផលិតកម្មនិងការនាំចេញកៅស៊ូឆ្នាំ២០១៦ ធៀបនឹងឆ្នាំ២០១៥

| បរិយាយ | 2015 | 2016 | % |
|---|---|---|---|
| ផ្ទៃដីដំណាំកៅស៊ូ (ហ.ត.) | 388.955 | 432.735 | 111,26 |
| ផ្ទៃដីចៀរ (ហ.ត.) | 111.232 | 126.996 | 114,17 |
| ផលិតផល (ត.) | 126.861 | 145.200 | 114,45 |
| ទិន្នផល (គ.ក្រ./ហ.ត.) | 1.141 | 1.143 | 100,18 |
| ផលិតផលនាំចេញ (ត.) | 128.047 | 145.100 | 113,32 |
| ទឹកប្រាក់សរុប (ដុល្លារ) | 150.043.980 | 187.164.551 | 124,74 |
| ថ្លៃកៅស៊ូ (ដុល្លារ/ត.) | 1.204 | 1.290 | 107,14 |

13

## ២. លទ្ធផល (ត)

**ការខារស្ថិតិ (ត)**

ផ្ទៃដីនិងផលិតផលកៅស៊ូឆ្នាំ២០០៧-២០២០




14

## ២. លទ្ធផល (ត)

**កត្តានាំឱ្យជោគជ័យ**



- ការគាំទ្រពីថ្នាក់ដឹកនាំ
- មានថវិកាគាំទ្រ
- ការសហការគ្នាល្អ
- ឆន្ទៈរបស់មន្ត្រី។






15

## ៣. បញ្ហាប្រឈម និងដំណោះស្រាយ

**តារាងម៉ាទ្រីក**

| បញ្ហាប្រឈម | ដំណោះស្រាយ | អង្គភាព ស្ថាប័ន ជួយដោះស្រាយ |
|---|---|---|
| ធនធានមនុស្ស និងមធ្យោបាយធ្វើការ នៅមានកម្រិត | ពង្រឹង និងបន្ថែមការផ្តល់ធនធានមនុស្ស និងមធ្យោបាយធ្វើការ | អ.ក. កសក. និងសហវ. |
| នីតិវិធីផ្តល់ ចំណាយ និងទូទាត់ថវិកា មិនទន់ភ្លន់ ស្មុគស្មាញ | កែសម្រួលនីតិវិធីផ្តល់ ចំណាយ និងទូទាត់ថវិកា ឱ្យទន់ភ្លន់ មិនស្មុគស្មាញ | កសក. និងសហវ. |
| ការរៀបចំ ការទូទាត់ និងការផ្តល់របាយការណ៍អនុវត្តថវិកាកម្មវិធីមកមិនទាន់ពេលវេលា | ជំរុញការរៀបចំ ការទូទាត់ និងការផ្តល់របាយការណ៍អនុវត្តថវិកាកម្មវិធីឱ្យទាន់ពេលវេលា និងការបង្កើនចំណេះដឹងដល់មន្ត្រីរាជការ | ក្រុមការងារ |
| កង្វះកិច្ចសហការពីក្រុមហ៊ុនវិនិយោគដាំកៅស៊ូលើដីសម្បទានសេដ្ឋកិច្ចក្នុងការផ្តល់ព័ត៌មាននិងទិន្នន័យពីដំណើរការវិនិយោគ | បន្តរៀបចំនិងពង្រឹងការអនុវត្តលិខិតគតិយុត្តពាក់ព័ន្ធ | អក. កសក. អាជ្ញាធរដែនដី និងមន្ទីរ កសក. ខេត្តពាក់ព័ន្ធ |
| ស្ថាប័នពាក់ព័ន្ធនិងអាជ្ញាធរដែនដីមិនទាន់បានសហការពេញលេញ | ជំរុញឱ្យមានកិច្ចសហការពេញលេញពីស្ថាប័នពាក់ព័ន្ធនិងអាជ្ញាធរដែនដី | អក. កសក. |

16

## ៤. សន្និដ្ឋាន

- ក្នុងឆ្នាំ២០១៦នេះ នាយកដ្ឋានផែនការ ហិរញ្ញវត្ថុ និងស្ថិតិ បានអនុវត្តសម្រេចទៅតាមទិសដៅ និងផែនការដែលបានកំណត់។
- លទ្ធផលទាំងនេះ មួយចំណែកធំគឺដោយសារការណែនាំពីថ្នាក់ដឹកនាំអគ្គនាយកដ្ឋានកៅស៊ូ និងការសហការពីមន្ត្រីគ្រប់ជាន់ថ្នាក់ ដែលនាំទទួលបាននូវលទ្ធផលជាផ្លែផ្កា និងមានប្រសិទ្ធភាពខ្ពស់។

17

## ៥. សំណូមពរ

- ផ្តល់ធនធានមនុស្ស និងមធ្យោបាយធ្វើការបន្ថែម
- បង្កើនថវិកាដើម្បីជំរុញការអភិវឌ្ឍឧស្សាហកម្មកៅស៊ូឱ្យកាន់តែប្រសើរ
- សូមផ្តល់របាយការណ៍អនុវត្តថវិកាកម្មវិធីឱ្យទាន់ពេលវេលា ដើម្បីងាយស្រួលដល់ការទូទាត់
- ស្នើសុំកិច្ចសហការក្នុងការផ្តល់របាយការណ៍ពីក្រុមហ៊ុនកសិឧស្សាហកម្ម និងក្រុមហ៊ុនសម្បទានដីសេដ្ឋកិច្ច
- បន្តសហការគ្នាល្អ។

18

## ៦. ទិសដៅ

- បន្តអនុវត្តចង្កោមសកម្មភាពអនុកម្មវិធី១.១៥
- បន្តសកម្មភាពពង្រឹងសមត្ថភាពមន្ត្រីក្នុងការរៀបចំនិងអនុវត្តថវិកាកម្មវិធី
- ជំរុញការផ្តល់គម្រោងផែនការឆ្នាំ២០១៨ និងរបាយការណ៍សមិទ្ធកម្មថវិកាកម្មវិធីឱ្យបានទាន់ពេលវេលាកំណត់
- អនុវត្តភារកិច្ចចរន្តនិងភារកិច្ចផ្សេងៗដែលថ្នាក់ដឹកនាំប្រគល់ឱ្យ។

19

## ៦. ទិសដៅ(ត)

គោលដៅនៃសូចនាករអនុកម្មវិធី ១.១៥ (ឆ្នាំ២០១៧)

| ល.រ. | សូចនាករលទ្ធផលក្នុងឆ្នាំ | ឯកតាវាស់វែង | គោលដៅ |
|---|---|---|---|
| ១ | ប្រសិទ្ធភាពនៃការអនុវត្តថវិកា | (%) | 94 |
| ២ | បណ្តុះបណ្តាលមន្ត្រីពីការងារគ្រប់គ្រងនិងអភិបាលកិច្ច | (វគ្គ) | 02 |

20

## ៦. ទិសដៅ(ត)

ចង្កោមសកម្មភាពនៃអនុកម្មវិធី ១.១៥ (ឆ្នាំ២០១៧)

| លរ. | ចង្កោមសកម្មភាព | ឯកតាវាស់វែង | គោលដៅ |
|---|---|---|---|
| ១ | តាមដានវឌ្ឍនភាពនៃការអនុវត្តចង្កោមសកម្មភាព | (លើក) | ១ |
| ២ | តាមដាននិងវាយតម្លៃការអនុវត្តកម្មវិធីវិនិយោគដីសម្បទានសេដ្ឋកិច្ចលើវិស័យកៅស៊ូ | (លើក) | ១១ |
| ៣ | គាំទ្រការសម្របសម្រួលការងារនិងរៀបចំប្រជុំបូកការងារ | (លើក) | ០១ |

21

### សកម្មភាពបណ្តុះបណ្តាលស្តីពីវិធីសាស្ត្រព្យាករណ៍ការផ្គត់ផ្គង់កៅស៊ូធម្មជាតិ





22

### សកម្មភាពបណ្តុះបណ្តាលស្តីពីនីតិវិធីរៀបចំថវិកាកម្មវិធី





23

### សកម្មភាពចុះពិនិត្យក្រុមហ៊ុនសម្បទានដីសេដ្ឋកិច្ច





24


សកម្មភាពចុះពិនិត្យ ការអនុវត្តសម្មភាពរបស់
ក្រុមអនុវត្តគម្រោង
25


សកម្មភាពចូលរួមប្រជុំ សិក្ខាសាលា និងសន្និសីទក្នុងប្រទេស
26


សកម្មភាពចូលរួមប្រជុំ សិក្ខាសាលា និងសន្និសីទក្រៅប្រទេស
27


សូមអរគុណ
28

# បទបង្ហាញទី៦ លទ្ធផលការងារឆ្នាំ២០១៦ និងលើកទិសដៅការងារឆ្នាំ២០១៧ របស់វិទ្យាស្ថានស្រាវជ្រាវកៅស៊ូកម្ពុជា

ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ

វិទ្យាស្ថានស្រាវជ្រាវកៅស៊ូកម្ពុជា



លទ្ធផលការងារឆ្នាំ២០១៦

និងទិសដៅការងារឆ្នាំ២០១៧



កិច្ចប្រជុំបូកសរុបការងារកៅស៊ូឆ្នាំ២០១៦ និងទិសដៅការងារឆ្នាំ២០១៧

អគ្គនាយកដ្ឋានកៅស៊ូ, ថ្ងៃទី២៧ ខែកុម្ភៈ ឆ្នាំ២០១៧

ឆេក ច័ន្ទ

## មាតិកា

1 • សេចក្តីផ្តើម
2 • លទ្ធផល
3 • បញ្ហាប្រឈម
4 • សន្និដ្ឋាន
5 • សំណូមពរ
6 • ទិសដៅអនុវត្តបន្តឆ្នាំ២០១៧
7 • រូបភាពសកម្មភាព

2

## ១- សេចក្តីផ្តើម

- នៅឆ្នាំ១៩៩១បន្ទាប់ពីសង្គ្រាមត្រូវបានបញ្ចប់ វិទ្យាស្ថានស្រាវជ្រាវកៅស៊ូកម្ពុជា (**វសកក**) ត្រូវបានបង្កើតឡើងវិញដោយប្រកាសលេខ១០៣១.៣៧០ចត.២ខ ចុះថ្ងៃទី១១ ខែតុលា និងក្លាយជាគ្រឹះស្ថានសាធារណៈរដ្ឋបាល(អនុក្រិត្យលេខ ៦៥អនក្រ.បក ចុះថ្ងៃទី១៧ ខែតុលា ឆ្នាំ១៩៩៧)
- នៅឆ្នាំ២០០១ **វសកក** ជាសមាជិកទី១៦ របស់ IRRDB
- ឆ្នាំ២០០៨ មន្ទីរពិសោធន៍ជាតិយថាប្រភេទនៃ **វសកក** ជាមន្ទីរពិសោធន៍ជាតិដំបូងគេ ដែលត្រូវបានទទួលស្គាល់តាមស្តង់ដារអន្តរជាតិ ISO/IEC 17025: 2005
- ឆ្នាំ ២០០៩ មន្ទីរពិសោធន៍ជាតិយថាប្រភេទត្រូវបានទទួលស្គាល់ជាមន្ទីរពិសោធន៍យោងនៅក្នុងតំបន់ចំពោះកៅស៊ូ TSR ដោយសមាគមកៅស៊ូអន្តរជាតិ IRA
- ឆ្នាំ២០១៦ កម្ពុជានឹងធ្វើជាម្ចាស់ផ្ទះលើកទី២ ក្នុងការរៀបចំសន្និសីទអន្តរជាតិ និងកិច្ចប្រជុំប្រចាំឆ្នាំរបស់ក្រុមប្រឹក្សាស្រាវជ្រាវ និងអភិវឌ្ឍកៅស៊ូអន្តរជាតិ ។

3

### ១.១ ស្ថានភាពបុគ្គលិក

- មន្ត្រី **វសកក** មានចំនួន**៥២នាក់** ក្នុងនោះមាន៖
  - ២៣នាក់ បំពេញការងារនៅភ្នំពេញក្នុងការិយាល័យចំនួន៣ រួមមាន មន្ទីរពិសោធន៍ជាតិយថាប្រភេទ, ការិ. រដ្ឋបាលបុគ្គលិក និងការិ.ផែនការ-គណនេយ្យ និង២៩នាក់ បំពេញការងារនៅស្ថានីយពិសោធន៍ ហើយនិងការិ.ស្រាវជ្រាវចំនួន៣ ផ្សេងទៀតរួមមាន ការិ. បង្កាត់ពូជ, ការិ.ដាំដុះនិងការពារ, ការិ.សរីរវិទ្យានិងអាជីវកម្ម។ មន្ត្រីទាំង៥២នាក់មានកម្រិតសញ្ញាបត្រ
    - បណ្ឌិត ០១នាក់
    - បរិញ្ញាបត្រជាន់ខ្ពស់ចំនួន ១០នាក់
    - បរិញ្ញាបត្រ ២៨នាក់
    - មធ្យមសិក្សាឯកទេស ០៦នាក់
    - មធ្យមសិក្សាទុតិយភូមិ ០៧នាក់
  - ➢ កម្មករអាជីវកម្ម កម្មករដាំដុះនិងកម្មករផ្សេងៗចំនួន២៦៨នាក់។

4

### ១.២ បេសកកម្ម

- **វសកក** មានបេសកកម្មដូចតទៅ៖
  - ទ្រទ្រង់ដល់ការអនុវត្ត រាល់កម្មវិធីអភិវឌ្ឍដំណាំកៅស៊ូ តាមការសិក្សាការតាមដានវាយតម្លៃ ការរៀបចំសម្របសម្រួលឯកសារបច្ចេកទេស និងហិរញ្ញវត្ថុ និងការធ្វើវិញ្ញាបនកម្មច្បារពូជ
  - ចាត់ចែងផ្តល់ពូជល្អៗ តាមរយៈការបញ្ចូល សាកល្បង បង្កើត បង្កើន និងផ្សព្វផ្សាយពូជ ការបង្កើតបទដ្ឋានស្តីពីគុណភាព
  - ចាត់ចែងមធ្យោបាយធ្វើលក្ខណៈវិនិច្ឆ័យ និងវិភាគ ចូលរួមសកម្មភាពក្នុងការបណ្តុះបណ្តាល ការផ្សព្វផ្សាយ ការផ្ទេរបច្ចេកវិទ្យាថ្មី តាមការផ្តួចផ្តើមគំនិតរបស់ខ្លួន ឬតាមសំណើរបស់ដៃគូក្នុង និងក្រៅប្រទេស ព្រមទាំងចាត់ចែងគ្រប់សកម្មភាពដែលជាអត្ថប្រយោជន៍ដល់ការអភិវឌ្ឍវិស័យកៅស៊ូ។

5

## ២. លទ្ធផល នៃការអនុវត្តថវិកាតាមកម្មវិធី

| លរ | ឈ្មោះសកម្មភាព | ឯកតា | ចំណុចដៅ | អនុវត្តការងារ | សម្រេច | |
|---|---|---|---|---|---|---|
| | | | | | ការងារ% | ថវិកា% |
| 1 | - រៀបចំច្បារបង្កាត់ពូជថ្មី ថែទាំ និងបង្កាត់ពូជ | កូន | 19 | 19 | 100 | 76,30 |
| 2 | - បង្កើតចំការពិសោធក្លូនទ្រង់ទ្រាយធំចំនួនពីរ | កូន | 53 | 14 | 26.4 | 98,28 |
| 3 | - តាមដាន និងស្រង់ទិន្នន័យចំការពិសោធន៍ប្រាំតំបន់ | តំបន់ | 5 | 5 | 100 | 84,88 |
| 4 | - គ្រប់គ្រងថែទាំច្បារពូជក្នុងស្ថានីយអនុវត្ត | ហ.ត | 6.6 | 6.6 | 100 | 96,00 |
| 5 | - គ្រប់គ្រង កៅស៊ូមិនទាន់ឲ្យផល និងថ្នាលបណ្តុះកូនកៅស៊ូ | ហ.ត | 157.2 | 157.2 | 100 | 93.66 |
| 6 | - ស្រាវជ្រាវការប្រើជីលើកៅស៊ូមិនទាន់ឲ្យផល និងកៅស៊ូឲ្យផល | ហ.ត | 20 | 20 | 100 | 100 |
| 7 | - បន្តការតាមដានចំការពិសោធន៍ផ្នែកដាំដុះ និងការពារ | ហ.ត | 44.8 | 44.8 | 100 | 100 |
| 8 | - ផ្សព្វផ្សាយបច្ចេកទេសដាំដុះ ថែទាំ និងជំងឺកៅស៊ូដល់កសិករ | នាក់ | 60 | 60 | 113 | 100 |
| 9 | - ពិសោធន៍ស្រាវជ្រាវលើគុណភាពដី(ដោយដំណាំគម្របដី) | ប្រភេទ | 4 | 4 | 100 | 100 |
| 10 | - ពិសោធន៍តាមដានប្រព័ន្ធចង្វាក់ចៀរជ័រឆ្វើលនៅស្ថានីយអនុវត្ត | ចំការ | 2 | 2 | 100 | 100 |
| 11 | - វិភាគសរីរៈទឹកជ័រកៅស៊ូចំការពិសោធន៍នានាក្នុងស្ថានីយ៍អនុវត្តន៍ | ដង | 2 | 2 | 100 | 100 |
| 12 | - បើកវគ្គបណ្តុះបណ្តាលបច្ចេកទេសប្រមូលផលទឹកជ័រ | នាក់ | 62 | 62 | 213 | 100 |
| 13 | - ធ្វើតេស្តគុណភាពជ័រប្រៀបធៀបអន្តរមន្ទីរពិសោធន៍ជាមួយ IRA | ដង | 2 | 2 | 100 | 100 |
| 14 | - រៀបចំនិងធ្វើតេស្តប្រៀបធៀបមន្ទីរពិសោធន៍ក្នុងស្រុក | ដង | 4 | 4 | 100 | 100 |
| 15 | - ចុះត្រួតពិនិត្យរោងចក្រ CSR និង Lab CSR | ដង | 2 | 2 | 100 | 100 |

- អនុកម្មវិធីទី១៦: លើកកម្ពស់គុណភាពពូជកៅស៊ូថ្មី និងប្រសិទ្ធភាព គុណភាពផលិតផលកៅស៊ូ (អនុកម្មវិធីនេះមានចំនួន ១៧សកម្មភាព ប៉ុន្តែសកម្មភាពទី១៦ និង១៧ ស្ថិតនៅក្នុងការទទួលធ្វើសវនកម្ម វិភាគទាន IRRDB និងចំណាយទូទៅដំណើរការស្រាវជ្រាវ)

6

**២.១ ផ្នែកក្សេត្រសាស្ត្រ**

- ការស្រង់ទិន្នន័យបញ្ចូលនិងវិភាគទិន្នន័យគ្រប់ចម្ការពិសោធន៍ចំនួន៦០ក្នុងបរិវេណស្ថានីយ៍អនុវត្ត និងនៅតាមណ្តាក្រុមហ៊ុន
- ការធ្វើតេស្តចៀរជ័រវាយតម្លៃទិន្នផលចម្ការពិសោធន៍ជម្រើសពូជបឋម(SET)
- ការដាំជួសកូនកៅស៊ូពិសោធន៍ក្លូនទ្រង់ទ្រាយធំ (PVAA01, PVAA02) នៅក្រុមហ៊ុន**ទ្រីភាពបឹងទន្លេម្រេច** ក្នុងស្រុករវៀង ខេត្តព្រះវិហារចំនួន ១៨៧៥ ដើម
- ការដាំជួសកូនកៅស៊ូនៅចម្ការពិសោធន៍ក្នុងស្ថានីយ៍ចំនួន៣១,៥ហ.ត
- ការស្រង់ទិន្នន័យជំងឺ *Oidium* នៅតាមបណ្តាចម្ការពិសោធន៍ក្លូន
- ការរៀបចំថ្នាលបណ្តុះកូនកៅស៊ូថ្មីសម្រាប់ឆ្នាំ២០១៥-២០១៦ ចំនួន ០,៣៥ហ.ត
- ការរៀបចំដាំដុះ និងគ្របគល់កូនកៅស៊ូចម្ការពិសោធន៍ថ្មីចំនួន ១៩ ហ.ត
- ការរៀបចំចម្ការពិសោធន៍ថ្មី ០១ នៅចម្ការកៅស៊ូក្រែក

7

**២.១ ផ្នែកក្សេត្រសាស្ត្រ(ត)**

- ការបាញ់ថ្នាំព្យាបាលជំងឺ ផ្កាកូលាប Pink Disease នៅតាមប្រគៀបមែកកៅស៊ូចាប់ពីកៅស៊ូអាយុ០៣ឆ្នាំ រហូតដល់អាជីវកម្មបានចំនួន០៤ជុំ លើផ្ទៃដី១៥០ហ.ត
- ការថែទាំកូនកៅស៊ូមិនទាន់ចំនួន១៣៧,៥ ហ.ត
- ការថែទាំចម្ការសមុច្ច័យដំណាំគ្របដីចំនួន១៧ប្រភេទ
- ការថែទាំ និងការតែងមែកច្បារបង្កាត់ពូជ
- ការការស្រង់ទិន្នន័យឧតុនិយម និងតំហែទាំឧបករណ៍ Sap Flow និង Flux Tower
- ការប្រមូលយកសំណាកទឹកជ័រតាមបណ្តាចម្ការពិសោធន៍ទាំងនៅក្នុងនិងក្រៅស្ថានីយ៍អនុវត្ត ដើម្បីធ្វើការវិភាគសរីរសាស្ត្រទឹកជ័រ (LD) បានចំនួន៩៨៦សំណាក
- វិភាគស្តង់ដាសរីរសាស្ត្រទឹកជ័រ ចំនួន២៦លើក ដើម្បីផ្ទៀងផ្ទាត់វត្ថុធាតុគីមី។



8




9

**២.២ ផ្នែកមន្ទីរពិសោធន៍ជាតិយថាប្រភេទ**

- ការធ្វើតេស្តយថាប្រភេទកៅស៊ូចំនួន ៣៧០ ភាគសំណាកសម្រាប់វាយតម្លៃគុណភាពកែច្នៃរបស់រោងចក្រ **CSR** និងពិនិត្យគុណភាពកៅស៊ូប្រភេទ RSS និងគុណភាពកៅស៊ូប្រភេទ CSR CV សម្រាប់និស្សិតកម្មសិក្សានិងការស្រាវជ្រាវ
- ការធ្វើតេស្តប្រៀបធៀបមន្ទីរពិសោធន៍ក្នុងស្រុក (Laboratories Parallel Test) ចំនួន៤លើក គឺលើកទី ៤៤, ៤៥, ៤៦ និងទី ៤៧ ដើម្បីវាយតម្លៃសមត្ថភាពមន្ទីរពិសោធន៍មូលដ្ឋាន
- ការធ្វើតេស្តអន្តរមន្ទីរពិសោធន៍ជាមួយ IRA ចំនួន២លើក(ទី១១៤ និង១១៥) ដើម្បីទទួលស្គាល់ជាមន្ទីរពិសោធន៍យោងនៅក្នុងតំបន់ចំពោះប្រភេទកៅស៊ូ TSRs
- ការត្រួតពិនិត្យតាមដាន និងវាយតម្លៃមន្ទីរពិសោធន៍មូលដ្ឋាន និងរោងចក្រកែច្នៃកៅស៊ូ CSR នៃក្រុមហ៊ុន **ស៊ីហ្វវីសសស៍ (ខេមបូឌា) លីមីតធីត** ចំការកៅស៊ូស្នួលចំនួន២លើក

10

**២.២ ផ្នែកមន្ទីរពិសោធន៍ជាតិយថាប្រភេទ(ត)**

- ការត្រួតពិនិត្យតាមដាន វាយតម្លៃ និងចុះបញ្ជិការោងចក្រកែច្នៃកៅស៊ូ **CSR** និងទទួលស្គាល់ មន្ទីរពិសោធន៍មូលដ្ឋាន នៃក្រុមហ៊ុន**ស៊ីធីរ៉ាប់ប៊ើរ ខូ., អិលធីឌី**
- ការចូលរួមការងារជាមួយជំនាញការនិងក្រុមវាយតម្លៃនៃគម្រោងអង្គការ UNIDO ក្នុងការរកដំណោះស្រាយ និងមូលហេតុលើឧបករណ៍ជំនួយដែលត្រូវធ្វើតេស្ត និងវាយតម្លៃទទួលស្គាល់ពី BoA
- ការចូលរួមប្រជុំក្រុមការងារបច្ចេកទេសផលិតផលកៅស៊ូ ក្នុងការកំណត់ស្តង់ដា និងសុខដុមរមនីយកម្មរបស់អាស៊ានចំនួន៤៦ស្តង់ដា សម្រាប់មន្ទីរពិសោធន៍យោងអាស៊ាន (ARLN: ASEAN Rubber Laboratory Network) នៅលើវិសាលភាពនៃ ISO/IEC 17025
- ការធ្វើបច្ចុប្បន្នភាពលើកម្រងព័ត៌មានសេវាសាធារណៈរបស់ **វសកក** ដើម្បីបញ្ចូលក្នុងប្រព័ន្ធស្មាតហ្វូនសម្រាប់ ការផ្សព្វផ្សាយព័ត៌មានផ្លូវការ

11

**២.២ ផ្នែកមន្ទីរពិសោធន៍ជាតិយថាប្រភេទ(ត)**

- ការទទួលនូវការត្រួតពិនិត្យ វាយតម្លៃលើតេស្តបន្ថែម និងអនុវត្តបំពេញលក្ខខណ្ឌតម្រូវការវិញ្ញាបនបត្រ ទទួលស្គាល់តាមស្តង់ដារអន្តរជាតិ ISO/IEC 17025:2005 ពីក្រុមត្រួតពិនិត្យ BoA សម្រាប់សមត្ថភាពមន្ទីរពិសោធន៍ ធ្វើតេស្ត និងព្យាសកម្មឧបករណ៍ និងបន្ថែមវិសាលភាពលើតេស្តកៅស៊ូសមាស និងផលិតផលកៅស៊ូ (Compound Rubber and Rubber Products) របស់មន្ទីរពិសោធន៍ជាតិយថាប្រភេទ សម្រាប់ការរក្សាសុពលភាពឆ្នាំ២០១៦
- ការរៀបចំអត្ថបទនៃការស្រាវជ្រាវឥទ្ធិពលអ៊ីដ្រុកស៊ីលអាមីនស៊ុលផាតណឺតលើការធ្វើវ៉ុលកានីសាស្យុងកៅស៊ូ សន្លឹក (RSS CV)។



12

## ២.៣ ផ្នែកបណ្តុះបណ្តាល

- រៀបចំវគ្គបណ្តុះបណ្តាលកសិករកៅស៊ូគ្រួសារចំនួន០៦វគ្គ ដោយកសិករអញ្ជើញចូលរួមវគ្គទាំង០៦ ជាសរុបមានចំនួន៣៧៥នាក់
- ការបញ្ជូនមន្ត្រី**វសកក**ចំនួន០៥រូបចូលរួមសិក្ខាសាលាអន្តរជាតិ IRRDB-Training ស្តីអំពី "វិធីសាស្ត្រក្នុងការសរសេរអត្ថបទបច្ចេកទេស ដើម្បីបោះពុម្ពផ្សាយ" ដែលប្រព្រឹត្តទៅនៅថ្ងៃទី២០ ខែវិច្ឆិកា ឆ្នាំ២០១៦ នៅខេត្ត**សៀមរាប**
- ការសរសេរអត្ថបទបច្ចេកទេស និងការធ្វើបទបង្ហាញចំនួន០៥ នៅក្នុងសន្និសីទប្រចាំឆ្នាំនៃក្រុមប្រឹក្សា ស្រាវជ្រាវ និងអភិវឌ្ឍកៅស៊ូអន្តរជាតិឆ្នាំ២០១៦។
- ចូលរួមវគ្គបណ្តុះបណ្តាលជាអ្នកវាយតម្លៃទទួលស្គាល់មន្ទីរពិសោធន៍និងព្យាសកម្ម ISO/IEC 17025 ដើម្បី ទទួលស្គាល់ជាអ្នកវាយតម្លៃថ្នាក់ជាតិ និងអន្តរជាតិ។
- ការចូលរួមសិក្ខាសាលាអន្តរជាតិរបស់មន្ត្រី **វសកក** ចំនួន០៧លើកនៅបណ្តាប្រទេសជាសមាជិកនៃ IRRDB

13

## ២.៣ ផ្នែកបណ្តុះបណ្តាល(ត)

- ការផ្ទេរបច្ចេកវិទ្យាដល់និស្សិតសាកលវិទ្យាល័យភូមិន្ទកសិកម្ម និងសាលាជាតិកសិកម្មកំពង់ចាមចំនួន១០០នាក់ ដែលមកបំពេញទស្សនកិច្ចសិក្សានៅស្ថានីយពិសោធន៍
- ការដឹកនាំនិស្សិតថ្នាក់បរិញ្ញាបត្រចំនួន១៣នាក់សរសេរសារណាបញ្ចប់ការសិក្សា
- បញ្ជូនថ្នាក់ដឹកនាំនិងមន្ត្រីជំនាញចំនួន០៦រូបទៅបណ្តុះបណ្តាលនិស្សិតនៅសាកលវិទ្យាល័យភូមិន្ទកសិកម្ម និងសាលាជាតិកសិកម្មកំពង់ចាម។






## ២.៤ កិច្ចសហប្រតិបត្តិការ

### ២.៤.១ កិច្ចសហប្រតិបត្តិការក្នុងក្របខណ្ឌ IRRDB

**វសកក** ជាសមាជិកទី១៦នៃ **IRRDB** នៅឆ្នាំ២០០១។ ក្នុងឆ្នាំ២០១៦ តាមការអញ្ជើញរបស់ **IRRDB** **វសកក** បានបញ្ជូនថ្នាក់ដឹកនាំនិងមន្ត្រីជំនាញឲ្យទៅចូលរួមសិក្ខាសាលា ការបណ្តុះបណ្តាលកិច្ចប្រជុំផ្សេងៗ និងសន្និសីទប្រចាំឆ្នាំចំនួន៧លើក។

កម្មវិធីប្តូរក្លូនពហុភាគីនៃ IRRDB **វសកក**បានផ្ញើមែកពូជCMS ចំនួន០៥ក្លូន ទៅឱ្យប្រទេសឥណ្ឌានិងថៃ ហើយទទួលបានមកវិញនូវក្លូនចំនួន១០ពីឥណ្ឌានិងថៃព្រមទាំងពូជCMSចំនួន០៣ក្លូន បន្ថែមទៀតពីCIRADតាមរយៈប្រទេស**ហ្គាណា**។

ប្រទេសកម្ពុជាទទួលវេនជាម្ចាស់ផ្ទះក្នុងការរៀបចំសន្និសីទ និងកិច្ចប្រជុំប្រចាំឆ្នាំ **IRRDB** ដែលបានប្រព្រឹត្តទៅកាលពីថ្ងៃទី២១-២៥ ខែវិច្ឆិកា ឆ្នាំ២០១៦នៅខេត្តសៀមរាមដោយមានភ្ញៀវជាតិ និងអន្តរជាតិចូលរួមចំនួន៣៣០នាក់។

15

### ២.៤ .២ កិច្ចសហប្រតិបត្តិការជាមួយ CIRAD

CIRAD បានផ្តល់កិច្ចអន្តរាគមន៍ជាច្រើនដល់ **វសកក** រួមមាន៖

- ផ្តល់ក្លូនកៅស៊ូប្រមាណ៤៣ដល់កម្ពុជា( ចំនួន០៦លើកចាប់ពី១៩៩២-២០១៦ )
- ផ្តល់ឧបករណ៍មន្ទីរពិសោធន៍ដល់មន្ទីរពិសោធន៍យថាប្រភេទជាតិ បណ្តុះបណ្តាលធនធានមនុស្ស និងជម្រុញឲ្យមានដំណើរការមន្ទីរពិសោធន៍គីមីជីវសរីរសាស្ត្រ។
- ដើម្បីជម្រុញឲ្យកិច្ចសហប្រតិបត្តិការនេះមានដំណើរកាន់តែល្អប្រសើរ និងជួយពង្រឹងសមត្ថភាពមន្ត្រី **វសកក** ឲ្យកាន់តែមានប្រសិទ្ធភាពបន្ថែមទៀត ការចុះហត្ថលេខាលើអនុស្សរណៈនៃការយោគយល់គ្នារវាង **វសកក** និងCIRAD ត្រូវបានធ្វើឡើងកាលពីថ្ងៃទី២២ ខែមិថុនា ឆ្នាំ២០១៦ នៅវិទ្យាស្ថានស្រាវជ្រាវកៅស៊ូកម្ពុជា។




16

### ២.៤ .៣ កិច្ចសហប្រតិបត្តិការជាមួយបណ្តាសាកលវិទ្យាល័យអន្តរជាតិ

- **វសកក** បានបន្តកិច្ចសហការជាមួយសាកលវិទ្យាល័យគ្យូស៊ូ ណាហ្គោយ៉ា និងសាកលវិទ្យាល័យហាវ៉ៃ លើការសិក្សាអំពីក្សេត្រសាស្ត្របរិស្ថានកៅស៊ូពាក់ព័ន្ធនឹង Sapflow, Stem flow through fall,...

### ២.៤ .៤ កិច្ចសហប្រតិបត្តិការជាមួយ UNIDO

- អង្គការនេះបានរួមចំណែកយ៉ាងសំខាន់ក្នុងការបណ្តុះបណ្តាលមន្ត្រីមន្ទីរពិសោធន៍ជាតិយថាប្រភេទ ផ្តល់កម្ចីសម្ភារៈ និងឧបករណ៍មន្ទីរពិសោធន៍ដល់ **វសកក** និងតម្រង់ទិសមន្ទីរពិសោធន៍ជាតិរហូតដល់ការទទួលបានវិញ្ញាបនបត្រ ISO/IEC 17025:2005 ពីការិយាល័យទទួលស្គាល់ BoA ។



17

### ២.៤ .៥ កិច្ចសហប្រតិបត្តិការជាមួយ CATAS

- **វសកក** និងCATAS បានចុះMoUកាលពីថ្ងៃទី០៨ ខែតុលា ឆ្នាំ២០១៣ ទីក្រុងកូឡុំបូ ប្រទេសស្រីលង្កា។ បន្ទាប់ពីនោះគណប្រតិភូ CATAS បានធ្វើទស្សនកិច្ចនៅ **វសកក** ចំនួន២លើក។ លើកទី១ នៅថ្ងៃទី១៧-២១ ខែធ្នូ ឆ្នាំ២០១៤ និងលើកទី២ នៅខែតុលាឆ្នាំ២០១៦ ដើម្បីស្វែងយល់ពីស្ថានភាព តម្រូវការ និងទិសដៅនៃការស្រាវជ្រាវរបស់នៃស្រាវជ្រាវរបស់ **វសកក** ដើម្បីរៀបចំគម្រោងសិក្សាស្រាវជ្រាវរួមគ្នាជាមួយ **វសកក** ដោយភាគីCATAS បានសន្យាខិតខំស្វែងរកគម្រោង និងថវិកាដើម្បីកសាងមជ្ឈមជាណ្ឌលសហប្រតិបត្តិការ និងមន្ទីរពិសោធន៍ ឲ្យចេញជារូបរាងនាពេលខាងមុខព្រមទាំងការបណ្តុះបណ្តាលធនធានមនុស្សដល់ **វសកក** ផងដែរ





18

## ៣. ការប្រឈម

- ការចុះថ្លៃនៃតម្លៃកៅស៊ូធម្ម-ជាតិ បង្កឲ្យមានការលំបាកក្នុងការគ្រប់គ្រងការងារពិសោធន៍និងការអភិវឌ្ឍរបស់ស្ថានីយពិសោធន៍ ហើយនិងផលប៉ះពាល់ជាអវិជ្ជមានដល់ជីវភាពរបស់កម្មករ និងបុគ្គលិក

- កង្វះមធ្យោបាយ សម្រាប់បម្រើការងារសិក្សាស្រាវជ្រាវ
- កង្វះធនធានមនុស្ស និង
- សមត្ថភាពយល់ដឹងរបស់មន្ត្រីនៅមានកម្រិត

- ទីតាំងពិសោធន៍ស្រាវជ្រាវចង្អៀត ទិន្នន័យពុំគ្រប់គ្រាន់។
- ភាគីដែលបានសហការរៀបចំការពិសោធន៍ពុំសូវយកចិត្តទុកដាក់នឹងការពិសោធន៍
- បណ្ដាក្រុមហ៊ុនកែច្នៃកៅស៊ូខ្វះការយកចិត្តទុកដាក់នឹងការពង្រឹងគុណភាពផលិតផលនិងវិញ្ញាបនបត្របញ្ជាក់យថាប្រភេទកៅស៊ូ។

19

## តុល្យភាពរវាងធនធានមនុស្ស និងការងារពិសោធន៍ស្រាវជ្រាវ




20

## ៤. សន្និដ្ឋាន

- ការងារអនុវត្តសម្រេចបានលើស១០០% ធៀបទៅនឹងចំណុចដៅដែលបានកំណត់នៅក្នុងផែនការថវិកាតាមកម្មវិធី
- ថវិកាកម្មវិធីអនុវត្តបានសម្រេចប្រមាណ៩០%
- សកម្មភាពជាច្រើនទៀតត្រូវបានអនុវត្តក្រៅពីផែនការដែលបានកំណត់នៅក្នុងកម្មវិធី
- មន្ត្រី **វសកក** មានភាពតស៊ូ ព្យាយាម និងអត់ធ្មត់ក្នុងការងារដែលញ៉ាំងឲ្យដំណើរការការងារមានភាពរលូន
- ថ្នាក់ដឹកនាំ និងមន្ត្រី**វសកក** មានសាមគ្គី ឯកភាពជាមួយគ្នា និងខិតខំបម្រើការងារអង្គភាពដោយរក្សាបាននូវវឌ្ឍនភាពការងារស្រាវជ្រាវទៅមុខជាលំដាប់៕

21

## ៥. សំណូមពរ

- ស្នើសូមឲ្យមានការលើកទឹកចិត្តដល់អ្នកស្រាវជ្រាវ
- ស្នើសូមផ្ដល់បន្ថែមក្របខណ្ឌមន្ត្រីដែលមានជំនាញ(កសិកម្ម, គីមី, យន្តសាស្ត្រ និតិសាស្ត្រ និងគណនេយ្យ)
- ស្នើអន្តរាគមន៍ផ្ដល់ផ្ទៃដីសម្រាប់សង់ស្ថានីយនិងការពិសោធន៍នៅតាមតំបន់ដែលមានសក្ដានុពលដំណាំកៅស៊ូ ដើម្បីកសាងទិន្នន័យឲ្យកាន់តែទូលំទូលាយ
- ស្នើសូមភ្នាក់ងារមានសមត្ថកិច្ចពាក់ព័ន្ធជួយទប់ស្កាត់ការនាំចេញផលិតផលកៅស៊ូដុំដែលគ្មានវិញ្ញាបនបត្របញ្ជាក់យថាប្រភេទកៅស៊ូ។

22

## ៦. ទិសដៅ

ដើម្បីសម្រេចនូវភារកិច្ចក្នុងឆ្នាំ២០១៧នេះ វិទ្យាស្ថានប្តេជ្ញាពុះពាររាល់ការលំបាកអនុវត្តឲ្យមានប្រសិទ្ធភាពនូវផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យកសិកម្ម២០១៤-២០១៨និងយុទ្ធសាស្ត្រចតុកោណរបស់រាជរដ្ឋាភិបាលដំណាក់កាលទី៣ ក្នុងការលើកស្ទួយវិស័យកៅស៊ូ ក្នុងនោះមានបណ្ដាភារកិច្ចមួយចំនួនខាងក្រោម៖

- ពង្រឹងការអនុវត្តភារកិច្ចស្នូលដូចមានក្នុងអនុក្រឹត្យគ្រឹះស្ថានសាធារណៈរដ្ឋបាលរបស់ **វសកក**
- ពង្រឹងកិច្ចពង្រឹងសកម្មភាពនៃការអនុវត្តថវិកាកម្មវិធីឱ្យមានប្រសិទ្ធភាព
- សហប្រតិបត្តិការជាមួយបណ្ដាប្រទេសសមាជិក IRRDB បណ្ដាអង្គការអន្តរជាតិ
- ខិតខំពង្រឹងភាពជាដៃគូស្រាវជ្រាវជាមួយបណ្ដាសាកលវិទ្យាល័យ ក្រុមហ៊ុន រោងចក្រកែច្នៃ ដើម្បីបង្កើនភាពជឿជាក់នូវសេវាបញ្ជាក់គុណភាពយថាប្រភេទ និងអន្តរាគមន៍រាល់សេវាបច្ចេកទេស បែបបទចុះបញ្ជិការោងចក្រ មន្ទីរពិសោធន៍ដើម្បីបានការទទួលស្គាល់ជាផ្លូវការពី **វសកក** ក្នុងការប្រើប្រាស់ស្លាកសញ្ញាយថាប្រភេទកៅស៊ូកម្ពុជា
- ធ្វើបច្ចុប្បន្នភាពអនុសាសន៍ក្លូនកៅស៊ូសម្រាប់ ឆ្នាំ២០១៧-២០២០។ រៀបចំចម្ការពិសោធន៍ទ្រង់ទ្រាយតូច និងការខិតខំជម្រុញនូវការអភិវឌ្ឍក្លូនកៅស៊ូកម្ពុជា
- បន្តកិច្ចប្រឹងប្រែងបណ្ដុះបណ្ដាលកសិករដើម្បីបង្កើនផលិតភាពនិងគុណភាពកៅស៊ូកម្ពុជា។

23

## ៧. រូបភាពសកម្មភាព



ឯកឧត្តម **វេង សាខុន** រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ អញ្ជើញជាអធិបតីក្នុងសន្និសីទអន្តរជាតិស្តីពី "និរន្តរភាពនៃឧស្សាហកម្មកៅស៊ូធម្មជាតិ បញ្ហា ការប្រឈម និងកាលានុវត្តភាព" នៅខេត្តសៀមរាប ពីថ្ងៃទី២១-២៥ ខែវិច្ឆិកា ឆ្នាំ២០១៦

24


ភ្ញៀវចូលរួមក្នុងអង្គសន្និសីទអន្តរជាតិ IRC 2016 នៅខេត្តសៀមរាប ពីថ្ងៃទី២១-២៥ ខែវិច្ឆិកា ឆ្នាំ២០១៦


ទស្សនកិច្ចភ្ញៀវនៃអង្គសន្និសីទអន្តរជាតិ IRC-2016 នៅចំការកៅស៊ូទ្រីភាពបឹងទន្លេម្រេច ខេត្តព្រះវិហារ


ឯកឧត្តម វេង សាខុន រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ អញ្ជើញសំណេះសំណាលជាមួយមន្ត្រីរាជការនិងធ្វើទស្សនកិច្ចចម្ការពិសោធន៍ ហើយនិងរោងចក្រកែច្នៃកៅស៊ូសន្លឹកនៅស្ថានីយ៍អនុវត្តនៃវិទ្យាស្ថានស្រាវជ្រាវកៅស៊ូកម្ពុជានៅស្រុកត្បូងឃ្មុំ ខេត្តត្បូងឃ្មុំ


៧. រូបភាពសកម្មភាព
មន្ត្រីវសកក ពិភាក្សាការងារជាមួយជំនាញការ CIRAD
ទស្សនកិច្ចរបស់ CIRAD នៅឡូត៍ពិសោធន៍នៃ វសកក
ជំនាញការ CIRAD បណ្តុះបណ្តាលមន្ត្រី វសកក អំពីការវិភាគ LD, Sucrose Pi, R-SH
ការវិភាគ LD, Sucrose Pi, R-SH
28


វគ្គបណ្តុះបណ្តាលកសិករកៅស៊ូគ្រួសារស្តីពីការគ្រប់គ្រងសមាសភាពចង្រៃនិងជម្ងឺកៅស៊ូ
វគ្គបណ្តុះបណ្តាលកសិករកៅស៊ូគ្រួសារស្តីពីការប្រមូលផលទឹកជ័រ និងការបើកមុខចៀរដំបូង
29


វិទ្យាស្ថានស្រាវជ្រាវកៅស៊ូកម្ពុជា
Rubber Research Institute of Cambodia
សូមអរគុណ...!

# រូបថតស្តីពីសកម្មភាពថ្នាក់ដឹកនាំអគ្គនាយកដ្ឋានកៅស៊ូ និងថ្នាក់ដឹកនាំ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ













# រូបថតស្តីពីសកម្មភាពថ្នាក់ដឹកនាំអគ្គនាយកដ្ឋានកៅស៊ូ និងថ្នាក់ដឹកនាំ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ(ត)











# រូបថតស្តីពីសកម្មភាពនាយកដ្ឋានអភិវឌ្ឍន៍កៅស៊ូ












# រូបថតស្តីពីសកម្មភាពនាយកដ្ឋានទីផ្សារ និងសហប្រតិបត្តិការអន្តរជាតិ











# រូបថតស្តីពីសកម្មភាពនាយកដ្ឋានកែច្នៃផលិតផលកៅស៊ូ











# រូបថតស្តីពីសកម្មភាពនាយកដ្ឋានរដ្ឋបាល និងនីតិកម្ម














# រូបថតស្តីពីសកម្មភាពនាយកដ្ឋានផែនការ ហិរញ្ញវត្ថុ និងស្ថិតិ












# រូបថតស្តីពីសកម្មភាពវិទ្យាស្ថានស្រាវជ្រាវកៅស៊ូកម្ពុជា














# រូបថតស្តីពីសកម្មភាពវិទ្យាស្ថានស្រាវជ្រាវកៅស៊ូកម្ពុជា ( ត )











**កៅស៊ូធម្មជាតិ គឺជាអ្នកផលិតភាពបៃតង**

Natural Rubber is a green producer

**កៅស៊ូធម្មជាតិ គឺជាមិត្តជិតស្និទ្ធជាមួយបរិស្ថាន**

Natural Rubber is an environmentally friendly

**កៅស៊ូធម្មជាតិ គឺជាផ្នែកមួយចាំបាច់នៃជីវិតប្រចាំថ្ងៃរបស់យើង**

Natural Rubber is an indispensable part of our daily life

**កៅស៊ូធម្មជាតិ ជួយទ្រទ្រង់ជីវភាពរស់នៅរបស់អ្នកផលិតនិងអ្នកប្រើប្រាស់**

Natural Rubber sustains livelihood of both producers and consumers

ផ្លូវជាតិលេខ៦អា ភូមិបាក់ខែង សង្កាត់ព្រែកលៀប ខណ្ឌជ្រោយចង្វារ រាជធានីភ្នំពេញ កម្ពុជា
National Road No.6A Phum Bakkheng, Sangkat Prek Leap, Khan Chroy Changva, Phnom Penh, Cambodia
ទូរស័ព្ទលេខ: (៨៥៥) ២៣ ៦៧២២ ៥៩០
Phone: (855) 23 6722 590, Email: gdr.maff@gmail.com